**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៦១) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 02-Oct-2020, 14:05
CMS/CFO: Sann Rada

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង០០៤**

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. HOLLIS
សហព្រះរាជអាជ្ញាអន្តរជាតិ

**ចម្លងជូន:**
លោកស្រី ជា លាង
សហព្រះរាជអាជ្ញាជាតិ

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**ចម្លងជូន:**
**សហមេធាវី យឹម ទិត្យ:**
ស៊ូ មូហ្សេទ្ធី
Suzana TOMANOVIĆ

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៃ**
**សំណុំរឿង០០៤**

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាសម្រេចលើកលែងចោទប្រកាន់") ដោយបានបដិសេធការចោទប្រកាន់នានាប្រឆាំងនឹង យឹម ទិត្យ ផ្អែកលើទឡ្ហីករណ៍ដែលថា "អ.វ.ត.ក មិនមានយុត្តាធិការលើ យឹម ទិត្យ ឡើយ"[1]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ដោយបានចោទប្រកាន់ យឹម ទិត្យ អំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និង ការរំលោភទៅលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងបានបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[2]។ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចេញដីកាសម្រេចរួមមួយបញ្ចប់ផ្នែកដែលនៅសេសសល់នៃសំណុំរឿង០០៤[3]។

2. យឹម ទិត្យ បានដាក់បណ្តឹងឧទ្ធរណ៍ចំនួនពីរ។ បណ្តឹងឧទ្ធរណ៍ទីមួយ ស្វែងរកការបដិសេធចោលដីកាដំណោះស្រាយទាំងពីរគឺ - ដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ - ផ្អែកលើមូលដ្ឋានដែលថា ស.ច.ស មិនត្រូវបានអនុញ្ញាតឲ្យចេញដីកាដំណោះស្រាយពីរខ្វែងគ្នានៅក្នុងសំណុំរឿង០០៤ នោះទេ ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយពីរ")[4]។ បណ្តឹងឧទ្ធរណ៍ទីពីរ ដែលប្រឆាំងតែទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ធ្វើការចោទប្រកាន់ទៅលើកំហុសខាងអង្គហេតុ និងអង្គច្បាប់ ក៏ដូចជាការរំលោភបំពានលើឆន្ទានុសិទ្ធិ ដែល យឹម ទិត្យ អះអាងថា តម្រូវឲ្យបដិសេធចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ[5]។

---

[1] ឯកសារ **D381** ដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ដីកាសម្រេចលើកលែងការចោទប្រកាន់") កថាខណ្ឌ ៦៨៦។

[2] ឯកសារ **D382** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") KH 01624968-80។

[3] ឯកសារ **D385** ដីកាសម្រេចបញ្ចប់កិច្ចស៊ើបសួរដែលនៅសេសសល់ទាំងអស់ក្នុងចំណោមកិច្ចស៊ើបសួរសំណុំរឿង០០៤ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

[4] ឯកសារ **D381/18 & D382/21** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ស្តីពីការចេញដីកាដំណោះស្រាយចំនួនពីរក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ")។

[5] ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ស្តីពីដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ស្តីពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

3. ចំពោះហេតុផលនានាដែលបានរៀបរាប់ខាងក្រោមនេះ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយពីរ គួរតែត្រូវបានបដិសេធចោល ដោយហេតុថា ដំណោះស្រាយដែលបានស្នើសុំ ផ្ទុយទៅនឹងភាសាធម្មតានៃកិច្ចព្រមព្រៀង អ.វ.ត.ក[6] ច្បាប់ អ.វ.ត.ក[7] និង វិធានផ្ទៃក្នុង[8] ក៏ដូចជាយុត្តិសាស្ត្រដ៏ស៊ីចង្វាក់គ្នារបស់ អ.វ.ត.ក ផងដែរ។

## II. ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ក្នុងសំណុំរឿង ០០៤/២ ស.ច.ស បានចេញដីកាសម្រេចរួមមួយលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ ដែលបានសម្រេចថា សហព្រះរាជអាជ្ញាមានសិទ្ធិចេញដីកាសន្និដ្ឋានស្ថាពរចំនួនពីរដាច់ដោយឡែក និងផ្ទុយគ្នា ហើយមិនតម្រូវឲ្យប្រើប្រាស់ការបំពេញបន្ថែមពេញលេញនៃវិធានការដោះស្រាយនានាតាមវិធាន៧១ នៃវិធានផ្ទៃក្នុងឡើយ[9]។ ការណ៍នេះត្រូវបានអនុវត្តតាមនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ដោយដីកាសម្រេចរួមមួយផ្សេងទៀត ដែល ស.ច.ស "[បាន]ពិចារណា ចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដូចដែលបានអនុញ្ញាតជាទូទៅតាមច្បាប់ជាធរមាន ជាពិសេសតាមសំអាងហេតុដែលយើងបានរកឃើញពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ថាពរផ្ទុយគ្នា"[10]។ ស.ច.ស បានរក្សាគោលជំហរនេះក្នុងរឿងក្តី ០០៤[11] ហើយនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ ពួកគាត់បានធ្វើកំណត់ហេតុនៃការខ្វែង

---

[6] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

[7] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ *ដូចដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី* ២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក")។

[8] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" "វិធាន" ឬ "IR(s)")។

[9] សំណុំរឿង០០៤/២-ឯកសារ **D353/1** ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ២៧, ៣៧, ៤២។ សម្រាប់សំអាងហេតុ *សូមមើល* កថាខណ្ឌ ២០-៣៧។

[10] សំណុំរឿង០០៤/២-ឯកសារ **D355/1** ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ១៤។

[11] *សូមមើល ឧទាហរណ៍* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៣។

យោបល់គ្នាមួយក្នុងសំណុំរឿង០០៤ ទាក់ទងនឹងការចេញដីកាដំណោះស្រាយដោយឡែកពីគ្នា និង ផ្ទុយគ្នា[12]។

5. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានចេញនូវសេចក្តីពិចារណារបស់ខ្លួន នៅក្នុងសំណុំរឿង ០០៤/២[13]។

6. ចំពោះផ្នែកសេសសល់នៃប្រវត្តិនីតិវិធី សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់បញ្ចូល តាមរយៈឯកសារយោងនូវប្រវត្តិនីតិវិធី ដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ I ភ្ជាប់ទៅនឹងបណ្តឹង ឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់[14]។

7. សំណៅបកប្រែជាភាសាខ្មែរនៃបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវបានជូនដំណឹងនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០[15] ធ្វើឱ្យចម្លើយតបនេះដល់កាលកំណត់ដាក់នៅ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០។

## III. ច្បាប់ជាធរមាន

8. ស.ព.អ បង្ហាញនៅទីនេះអំពីបទប្បញ្ញត្តិសំខាន់ៗពាក់ព័ន្ធទៅនឹងដំណោះស្រាយនៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយពីររបស់ យឹម ទិត្យ។ ច្បាប់ជាធរមានដែលនៅសេសសល់ត្រូវបាន រៀបរាប់នៅក្នុងផ្នែកដែលពាក់ព័ន្ធនានាខាងក្រោម។

### *ភាពអាចទទួលយកបាន*

9. អនុលោមតាមវិធាន៧៤(៣) នៃវិធានផ្ទៃក្នុង ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្តីសម្រេចរបស់ ស.ច.ស មួយចំនួន រួមទាំងសេចក្តីសម្រេចស្តីពី "ការបញ្ជាក់ពីយុត្តាធិការ របស់ អ.វ.ត.ក" ផង[16]។

---

[12] ឯកសារ **D382** ដីកាដំណោះស្រាយ កថាខណ្ឌ ២១។ *សូមមើលបន្ថែមទៀត* ឯកសារ **D381** ដីកាសម្រេចលើកលែងការចោទប្រកាន់ កថាខណ្ឌ ១៣។

[13] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន*")។

[14] ឯកសារ **D381/19.2** ឧបសម្ព័ន្ធ I៖ ប្រវត្តិនីតិវិធី ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩។

[15] *សូមមើល* អ៊ីម៉ែលជូនដំណឹងពីមន្ត្រីគ្រប់គ្រងសំណុំរឿង ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង ១០:៣៤នាទីព្រឹក។

[16] វិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

10. អ.ប.ជ ធ្លាប់បានសម្រេចពីមុនមក[17] ថា នៅក្នុងកាលៈទេសៈដ៏កម្រមួយចំនួនដែលអង្គហេតុនៃរឿងក្តីមួយបានលើកឡើងបញ្ហាមួយចំនួនអំពីសិទ្ធិជាមូលដ្ឋាន ឬ បញ្ហាធ្ងន់ធ្ងរស្តីពីភាពត្រឹមត្រូវផ្នែកនីតិវិធីនោះ ការបកស្រាយបែបសេរីនិយមនៃសិទ្ធិប្តឹងឧទ្ធរណ៍នៅក្នុងវិធាន៧៤(៣) នៃវិធានផ្ទៃក្នុង អាចនឹងត្រូវបានអនុញ្ញាតដើម្បីធានាថាកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ និងប្រតិប័ក្ស ស្របគ្នាទៅនឹងគោលការណ៍ជាមូលដ្ឋាន ដែលមានចែងនៅក្នុងវិធាន២១ នៃវិធានផ្ទៃក្នុង។ គោលការណ៍ទាំងនេះឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះដ៏ត្រឹមត្រូវដែល អ.វ.ត.ក ជាប់កាតព្វកិច្ចអនុវត្តអនុលោមតាមមាត្រា១៣(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា៣៣ថ្មី និង ៣៥ថ្មី នៃច្បាប់ អ.វ.ត.ក ហើយនិង មាត្រា១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[18]។ យ៉ាងណាក៏ដោយ អ.ប.ជ បានរំលឹកជាញឹកញាប់ថា វិធាន២១ មិនបានផ្តល់នូវផ្លូវជាស្វ័យប្រវត្តិមួយសម្រាប់បណ្តឹងឧទ្ធរណ៍នោះទេ សូម្បីតែក្នុងករណីដែលបណ្តឹងឧទ្ធរណ៍លើកឡើងពីបញ្ហាការជំនុំជម្រះដ៏ត្រឹមត្រូវ[19] និងថាករណីនិមួយៗត្រូវតែបានវាយតម្លៃដើម្បីកំណត់

---

[17] *សូមមើល ឧទាហរណ៍* សំណុំរឿង០០៣-ឯកសារ **D128/1/9** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [កោសលុប] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ [កោសលុប] *ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ស្តីពីការចោទប្រកាន់ក្នុងសំណុំរឿង០០៣") កថាខណ្ឌ ២០ និងការលើកឡើងនៅក្នុងនោះ។ សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ៤៩ និងការលើកឡើងនៅក្នុងនោះ។ សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៤៦ (ជាឯកច្ឆ័ន្ទ)។

[18] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ទីក្រុង New York ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ 999 UNTS 171។

[19] *សូមមើល ឧទា.* សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៤៧ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០៣-ឯកសារ **D128/1/9** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ស្តីពីការចោទប្រកាន់ក្នុងសំណុំរឿង០០៣ កថាខណ្ឌ ២០។ ឯកសារ **D208/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ទាក់ទងនឹងករណីខ្វែងយោបល់គ្នា") កថាខណ្ឌ ៨។ សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៩។

ថាតើ ជារួម អង្គហេតុ និង កាលៈទេសៈបានធានាដល់ការបកស្រាយដ៏ទូលំទូលាយមួយស្តីពីសិទ្ធិប្តឹងឧទ្ធរណ៍ដែរ ឬយ៉ាងណា[20]។

11. ដើម្បីឲ្យ អ.ប.ជ ទទួលយកបណ្តឹងឧទ្ធរណ៍មួយមកពិនិត្យតាមការបកស្រាយដ៏ទូលំទូលាយនៃវិធាន៧៤(៣) តាមស្មារតីនៃវិធាន២១ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវតែបង្ហាញថា ស្ថានភាពដែលជាបញ្ហានោះគឺមិនត្រូវបានគិតទុកជាមុនដោយច្បាប់ជាធរមាន និងថាកាលៈទេសៈជាក់ស្តែងនៃករណីនោះតម្រូវឲ្យមានអន្តរាគមន៍របស់អង្គជំនុំជម្រះ នៅដំណាក់កាលនោះ នៅពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ដើម្បីជៀសវាងការខូចខាត*ដែលមិនអាចជួសជុលបាន* ទៅលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ឬទៅលើសិទ្ធិជាមូលដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍[21]។ ដោយឡែក ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមវិធាន៧៤ នៃវិធានផ្ទៃក្នុង លើកឡើងអំពីបញ្ហាដែលមិនអាចត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ដែលនាំឲ្យ មានព្យសនកម្មមិនអាចជួសជុលបានចំពោះសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវរបស់ជនជាប់ចោទនោះ វិធាន ២១ នៃវិធានផ្ទៃក្នុង អាចធានាឲ្យមានការស្នើសុំឲ្យពង្រីកវិសាលភាពនៃវិធាន៧៤ នៃវិធានផ្ទៃក្នុង[22]។

12. នៅក្នុងសេចក្តីពិចារណាលើសំណុំរឿង០០៤/២ របស់ខ្លួន អ.ប.ជ បានរកឃើញជាឯកច្ឆ័ន្ទថា ទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន ដែលជំទាស់ទៅនឹងការចេញដីកាដំណោះស្រាយចំនួនពីរនោះ គឺអាចទទួលយកបានតាមការបកស្រាយដ៏ទូលំទូលាយមួយនៃវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង តាមស្មារតីនៃវិធាន២១ នៃវិធានផ្ទៃក្នុង។ អ.ប.ជ បានធ្វើដូច្នេះ ផ្អែកលើមូលដ្ឋានដែលថា ការចេញដីកាដំណោះស្រាយចំនួនពីរ គឺជាស្ថានភាពថ្មីមួយនៅចំពោះមុខ អ.វ.ត.ក

---

[20] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៩ និងការលើកឡើងនៅក្នុងនោះ។ *សូមមើលផងដែរ* សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៤៧ (ជាឯកច្ឆ័ន្ទ)។

[21] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តី ពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៤៦-១៤៧ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០៣-ឯកសារ **D128/1/9** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ស្តីពីការចោទប្រកាន់ក្នុងសំណុំរឿង០០៣ កថាខណ្ឌ ២០។ ឯកសារ **D208/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ទាក់ទងនឹងករណីខ្វែងយោបល់គ្នា កថាខណ្ឌ ៨។

[22] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤៨។

ដែលមិនត្រូវបានគិតទុកជាមុននៅក្នុងវិធានផ្ទៃក្នុង និងអាចតម្រូវឲ្យមានដំណោះស្រាយមួយនៅមុនការជំនុំជម្រះ ដើម្បីការពារកុំឲ្យមានផលប៉ះពាល់ដែលមិនអាចកែប្រែបានដល់សិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវរបស់ អោ អាន ដោយរួមបញ្ចូលទាំងលទ្ធភាពរបស់គាត់ក្នុងការត្រៀមរៀបចំសម្រាប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ ហើយនិងភាពត្រឹមត្រូវដ៏ពេញលេញនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[23]។

## *បទដ្ឋាននៃការពិនិត្យឡើងវិញ*

13. អ.ប.ជ ធ្លាប់បានសម្រេចថា៖

> សេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិអាចត្រូវបានបដិសេធចោល ក្នុងករណីដែលសេចក្ដីសម្រេចនោះ (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (គឺកំហុសអង្គច្បាប់) ដែលនាំឲ្យសេចក្ដីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត (គឺកំហុសអង្គហេតុ) ដែលបណ្ដាលឲ្យមានភាពមិនយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុសមផល ដែលជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឲ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានប្រយ័ត្នប្រយែង។ អាចនិយាយម្យ៉ាងទៀតថា ត្រូវបង្ហាញឲ្យឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុស ឬមានការបំពាន ដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[24]។

14. នៅក្នុងបរិបទនៃសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិ អ.ប.ជ អាចនឹងបញ្ជូនសេចក្ដីសម្រេចនោះត្រឡប់ទៅឲ្យ ស.ច.ស ដើម្បីធ្វើការពិចារណាឡើងវិញ ហើយនឹងដាក់សេចក្ដីសម្រេចរបស់ខ្លួនជំនួសតែនៅក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ។ នៅក្នុងករណីជាក់លាក់នៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា

---

[23] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៣៣, ១៤៩ (ជាឯកច្ឆ័ន្ទ)។

[24] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ២៨-២៩ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ("សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់*អ៊ឹម ចែម*") កថាខណ្ឌ ២០-២១ (ជាឯកច្ឆ័ន្ទ)។

ដំណោះស្រាយ អ.ប.ជ បានសម្រេចថា វិធាន៧៩(១) នៃវិធានផ្ទៃក្នុងណែនាំថា អ.ប.ជ មានអំណាចចេញដីកាដំណោះស្រាយមួយថ្មី ឬ ដីកាដំណោះស្រាយដែលកែប្រែឡើងវិញ ដែលនឹងប្រើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះ[25]។

15. អ.ប.ជ ក៏បានបញ្ជាក់ផងដែរថា តួនាទីរបស់ខ្លួនមិនត្រូវបានកំណត់ត្រឹមតែការពិចារណាលើអង្គសេចក្តីនៃសារណាលើបណ្តឹងឧទ្ធរណ៍របស់ភាគីនោះទេ[26]។ នៅក្នុងសេចក្តីពិចារណាក្នុងសំណុំរឿង០០៤/២ ថ្មីៗនេះ អ.ប.ជ បានសម្រេចថា ខ្លួន "ជាយុត្តាធិការចុងក្រោយបង្អស់លើដំណាក់កាលបុរេជំនុំជម្រះនៅ អ.វ.ត.ក"[27] និង "អនុវត្តអំណាចចុងក្រោយនៅដំណាក់កាលស៊ើបសួរ"[28]។ បែបដូច្នោះ នៅក្នុងដំណាក់កាលស៊ើបអង្កេត ខ្លួនត្រូវទទួលខុសត្រូវចំពោះការធានាថា គោលការណ៍ជាមូលដ្ឋានដែលជាមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌដែលជាធរមាននៅចំពោះមុខ អ.វ.ត.ក គឺត្រូវបានគោរព[29]។ អង្គជំនុំជម្រះយល់ឃើញថា អំណាចនៃការពិនិត្យឡើងវិញរបស់ខ្លួនក្នុងឋានៈជាសភាស៊ើបសួរត្រូវបានបម្រុងទុក[30] ជាដំបូង និងសំខាន់បំផុតនោះគឺដើម្បីឲ្យប្រាកដថា លក្ខខណ្ឌនានាសម្រាប់ការចេញដីកាដំណោះស្រាយ និង ការស៊ើបអង្កេតដែលបានត្រៀមទុក គឺស្របទៅតាមវិធាន២១ និង ៧៦ នៃវិធានផ្ទៃក្នុង និង មាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[31]។

---

[25] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៣០ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អ៊ឹម ចែម* កថាខណ្ឌ ២២ (ជាឯកច្ឆ័ន្ទ)។

[26] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៥០ (ជាឯកច្ឆ័ន្ទ)។

[27] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៤១ (ជាឯកច្ឆ័ន្ទ)។

[28] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៤៩ (ជាឯកច្ឆ័ន្ទ)។

[29] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៥២ (ជាឯកច្ឆ័ន្ទ)។

[30] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៤៤ (ជាឯកច្ឆ័ន្ទ)។

[31] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៥០ (ជាឯកច្ឆ័ន្ទ)។ *សូមមើលបន្ថែមទៀត* កថាខណ្ឌ ៤៧-៤៨, ៥១, ៨៩ (ជាឯកច្ឆ័ន្ទ)។

## អង្គសេចក្តី

16. មាត្រា ៥ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

១-មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត។ [...]

៤-សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងពីរនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧។

17. មាត្រា ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

១-ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាបានធ្វើសំណើស្របតាមមាត្រា ៥ វាក្យខណ្ឌ ៤ ឬមាត្រា ៦ វាក្យខណ្ឌ ៤ តាមករណីដែលកើតឡើង [...]

២-ការខ្វែងគំនិតគ្នានេះ នឹងត្រូវដោះស្រាយជាបន្ទាន់ដោយ "អង្គបុរេជំនុំជម្រះ" មួយមានចៅក្រមប្រាំរូប [...]

៤-ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា នឹងត្រូវដំណើរការភ្លាមៗស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើន ដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេ ការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត។

18. មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖

រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ [...]

ក្នុងករណីដែលមានភាពមិនស្រុះគ្នា រវាងសហចៅក្រម[ស៊ើបអង្កេត] ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូប ក្នុងចំណោមពួកគេពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម៖
[…]

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឲ្យមានសម្លេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច។ […] សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឲ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត។

19. វិធាន១(២) នៃវិធានផ្ទៃក្នុង ចែងថា “លើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅ ក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេត ទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងសហចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នក ទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង”។

20. វិធាន២១ នៃវិធានផ្ទៃក្នុង ចែងដោយផ្នែកថា៖

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង កិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និង អាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។ [...]

ឃ-ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។

21. វិធាន៦៧(១) នៃវិធានផ្ទៃក្នុង ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖ “សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់”។

22. វិធាន៧៧(១៣) នៃវិធានផ្ទៃក្នុង ចែងថា៖

សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូប យ៉ាងតិច។ សេចក្ដីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្ដីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវអនុវត្តដូចខាងក្រោម៖

ក-ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ ឬ ពាក្យសុំមោឃភាពដីកា ឬ កិច្ចស៊ើបសួរដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកា ឬ កិច្ចស៊ើបសួរនោះ ត្រូវតម្កល់ទុកជាបានការ។

ខ-ក្នុងករណីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

23. វិធាន៧៩(១) នៃវិធានផ្ទៃក្នុង ផ្ដល់អំណាចថា “អង្គជំនុំជម្រះសាលាដំបូងទទួលបណ្ដឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ”។

## IV. សារណា

### *ភាពអាចទទួលយកបាន*

24. តាមដីកាសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ នៅក្នុងសំណុំរឿង០០៤/២ ដែលថា បណ្តឹងឧទ្ធរណ៍មួយប្រឆាំងនឹងនីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយចំនួនពីរដាច់ដោយឡែកពីគ្នា គឺអាចទទួលយកបាន អនុលោមតាមវិធាន៧៤(៣)(ក) នៃវិធានផ្ទៃក្នុង នៅពេលដែលត្រូវបានបកស្រាយតាមស្មារតីនៃវិធាន២១[32] នៃវិធានផ្ទៃក្នុងនោះ ស.ព.អ មិនជំទាស់ទៅនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរនេះទេ។

### *អង្គសេចក្តី*

25. វាគឺជាគោលជំហរដ៏ស៊ីចង្វាក់គ្នារបស់ ស.ព.អ រូបនេះ និង ស.ព.អ មុនគាត់[33] ដែលថា ស.ច.ស ពិតជាអាចចេញដីកាដំណោះស្រាយពីរខ្វែងគ្នា។ ស.ព.អ បាន ប្រកាន់នូវទស្សនៈមួយថា នេះគឺជាការបកស្រាយយ៉ាងសាមញ្ញបំផុតនូវវិធាន៦៧(១)[34] នៃវិធានផ្ទៃក្នុង នៅពេលដែលអានតាមស្មារតីនៃវិធាន១(២) នៃវិធានផ្ទៃក្នុង ដែលបានចែងថា នៅក្នុងវិធានផ្ទៃក្នុងទាំងមូល "*ជាពិសេស លើកលែងតែមានចែងផ្សេងពីនេះ* ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា *និងសហចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ* ទោះបី*ដោយផ្ទាល់* ឬតាមរយៈតំណាង"[35]។ ទស្សនៈរបស់ ស.ព.អ ក៏ត្រូវបានជូនដំណឹងផងដែរអំពីការខ្វល់ខ្វាយរបស់ខ្លួនដែលថា គុណវិបត្តិនៃការតម្រូវឲ្យមានដីកាដំណោះស្រាយមួយគឺមានសារៈសំខាន់ នៅពេលដែលប្រឈមជាមួយនឹងគោលជំហរពីរផ្ទុយគ្នាទាំងស្រុង លើបញ្ហាថាតើវាជាការត្រឹមត្រូវដែរឬទេ

---

[32] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៣៣, ១៤៩ (ជាឯកច្ឆ័ន្ទ)។

[33] *សូមមើល ឧទា.* សំណុំរឿង០០៤/២-ឯកសារ **D360/9** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩។ សំណុំរឿង០០៤/២-ឯកសារ **D359/9.1** ប្រតិចារឹក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ម៉ោង៖ 13.27.29-13.36.37។

[34] វិធាន៦៧(១) នៃវិធានផ្ទៃក្នុង ("សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ ថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់")។

[35] ការសង្កត់ន័យត្រូវបានបន្ថែម។

ក្នុងការចោទប្រកាន់បុគ្គលម្នាក់។ គុណវិបត្តិទាំងអស់នេះរួមមាន (i) គ្រោះថ្នាក់នៃការរំលោភបំពានលើគោលការណ៍ឯករាជភាពតុលាការ ដែលត្រូវបានធានាដោយក្របខណ្ឌច្បាប់ អ.វ.ត.ក[36] និងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា[37] ប្រសិនបើចៅក្រមណាម្នាក់ត្រូវបានតម្រូវឲ្យបោះបង់សិទ្ធិ និងកាតព្វកិច្ចឯករាជរបស់ពួកគាត់ ដើម្បីបិទបញ្ចប់ការស៊ើបអង្កេតតាមរបៀបមួយ ដែលពួកគាត់កំណត់ថាត្រូវបានតម្រូវដោយច្បាប់ និងអង្គហេតុ ដែលពួកគាត់ត្រូវបានប្ដឹងឲ្យទទួលយក និង/ឬ (ii) ការធ្វើឲ្យខូចខាតដល់តម្លាភាព ព្រោះថាយន្តការផ្លូវការនៃការខ្វែងយោបល់គ្នាអាចនឹងធ្វើឲ្យទស្សនៈខ្វែងគ្នាដែលតំណាងដោយដីកាដំណោះស្រាយ ដែលបានស្នើឡើងនេះទៅជារឿងសម្ងាត់ ហើយប្រហែលជាធ្វើឲ្យដំណោះស្រាយរបស់ អ.ប.ជ លើការខ្វែងយោបល់គ្នារបស់ ស.ច.ស ទៅជាសម្ងាត់ដែរ[38]។ បន្ទាប់ពីដំណើរការនេះមក គឺមានតែដីកាដំណោះស្រាយដែលត្រូវបានទទួល

---

[36] កិច្ចព្រមព្រៀងអ.វ.ត.ក មាត្រា៣(៣) (“ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត [...] ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន មិងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ”) មាត្រា៥(២) (“សហចៅក្រមស៊ើបអង្កេត ត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់មិនលំអៀង និងសុចរិត”) មាត្រា៥(៣) (“សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតបានឡើយ”)។ ច្បាប់អ.វ.ត.ក មាត្រា១០ថ្មី (“ចៅក្រមជម្រះក្ដីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ”) មាត្រា១២ (“ចៅក្រមជម្រះក្ដីទាំងអស់ ដែលស្ថិតក្រោមច្បាប់នេះ មានឋានៈ និងលក្ខខណ្ឌការងារស្មោះៗគ្នាទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ”) មាត្រា២៥ (“សហចៅក្រមស៊ើបអង្កេត [...] ត្រូវមានចរិតលក្ខណៈ និងស្មារតីខ្ពស់ ចរិតមានបទពិសោធន៍ក្នុងការងារជំនាញ។ សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួនហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ”)។

[37] ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៥១ (“អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចប្រតិបត្តិ និងអំណាចតុលាការ”) មាត្រា១២៨ (“អំណាចតុលាការ ធានារក្សាអនាគតិ និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ”) មាត្រា១២៩ (“មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្ដី”) មាត្រា១៣០ (“គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ)។

[38] វិធាន៧២(២) នៃវិធានផ្ទៃក្នុង (“ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ លើកលែងតែក្នុងករណីដែលមានចែងក្នុងអនុវិធាន៤(ខ) ខាងក្រោម”) វិធាន៧២(៤) (“អង្គបុរេជំនុំជម្រះ ត្រូវដោះស្រាយបញ្ហាខ្វែងយោបល់នេះ ដូចខាងក្រោម៖ ក-សវនាការរបស់អង្គបុរេជំនុំជម្រះត្រូវរៀបចំធ្វើឡើង និងប្រកាសសាលក្រម*ជាសម្ងាត់*។ ខ-នៅពេលមានការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការសម្រេចសេចក្ដី ដែលភាគីនៃសំណុំរឿងមានសិទ្ធិប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះតាមវិធានផ្ទៃក្នុងនេះ ត្រូវអនុវត្តដូចខាងក្រោម៖ [...] (៤) ដោយផ្អែកតាមសំណើរបស់ចៅក្រម ឬ ភាគីណាមួយ អង្គបុរេជំនុំជម្រះ*អាច*សម្រេចថា ផ្នែកទាំងមូល ឬ ផ្នែកណាមួយនៃសវនាការត្រូវធ្វើឡើងជា

យកដោយ អ.ប.ជ ឬ ដីកាដំណោះស្រាយមួយដែលត្រូវបានផ្តល់សុពលភាពដោយគោលជំហរស្វ័យប្រវត្តិថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត" ត្រូវបានផ្សព្វផ្សាយ[39]។

26. យ៉ាងណាក៏ដោយ ស.ព.អ បានដឹងអំពីសេចក្តីប្រកាសជាឯកច្ឆ័ន្ទនាពេលថ្មីៗនេះរបស់ អ.ប.ជ នៅក្នុងសំណុំរឿង០០៤/២ នៅក្នុងកាលៈទេសៈដែលដូចគ្នាតាមកិច្ចដំណើរការនីតិវិធីបេះបិទទៅនឹងសំណុំរឿង០០៤ ដែលថា *ការចេញ* ដីកាដំណោះស្រាយពីរខ្វែងគ្នារបស់ ស.ច.ស គឺ "ខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក"[40]។ អ.ប.ជ បាន

---

សាធារណៈ ជាពិសេសក្នុងករណី ដែលរឿងក្តីអាចត្រូវបញ្ចប់ដោយសេចក្តីសម្រេចរបស់ខ្លួន ដូចជាក្នុងករណីបណ្តឹងឧទ្ធរណ៍ ឬ ពាក្យស្នើសុំដែលពាក់ព័ន្ធនឹងយុត្តាធិការ ឬ ការរលត់បណ្តឹងអាជ្ញា *ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា សវនាការបែបនេះគឺធ្វើឡើងក្នុងប្រយោជន៍ដើម្បីយុត្តិធម៌ និងមិនប៉ះពាល់ សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការណ៍ការពារណាមួយដែលអនុញ្ញាតដោយតុលាការ។* [...] ង) រាល់សេចក្តីសម្រេចទាំងអស់ដែលមានចែងក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផង ត្រូវមានបញ្ជាក់ពីមូលហេតុ និង ចុះហត្ថលេខាដោយសាម៉ីខ្លួន។ ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះត្រូវបញ្ជូនសេចក្តីសម្រេចនេះទៅប្រធានការិយាល័យរដ្ឋបាល ដែលត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត")។ វិធាន៧៨ ("រាល់សេចក្តីសម្រេចដែលមានសំលេងគាំទ្រគ្រប់គ្រាន់ និង រាល់សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់របស់អង្គបុរេជំនុំជម្រះរួមទាំងមតិជំទាស់ផងត្រូវបោះពុម្ពផ្សាយទាំងស្រុង *លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ ដល់ផលប្រយោជន៍នៃការអង្កេតបឋម ឬ ការស៊ើបសួរ*" (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* វិធាន៥៦(១) នៃវិធានផ្ទៃក្នុង ("ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឱ្យបាននូវការសម្ងាត់")។ *សូមមើលបន្ថែមទៀត* ឯកសារ **D1/1.3** ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ("ការពិចារណារបស់ អ.ប.ជ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ៤៦ ("យោងតាមបទប្បញ្ញត្តិទាំងនេះ [វិធាន៧១(២) និង ៥៦(១) នៃវិធានផ្ទៃក្នុង] ឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា ត្រូវបានអង្គបុរេជំនុំជម្រះចាត់ចំណាត់ថ្នាក់ថាជា"ឯកសារសម្ងាត់បំផុត"") កថាខណ្ឌ៥២-៥៣ (ដោយផ្តល់អនុសាសន៍ឱ្យផ្សព្វផ្សាយនូវសំណៅកោសលុបនៃសេចក្តីពិចារណា ដោយគិតទៅដល់ពេលមុនសេចក្តីប្រកាសព័ត៌មានដែលត្រូវបានចេញដោយសហព្រះរាជអាជ្ញា ប៉ុន្តែកត់សម្គាល់ថា "ការបោះពុម្ពផ្សាយសេចក្តីពិចារណារបស់អង្គបុរជំនុំជម្រះ គឺជាអំណាចឆន្ទានុសិទ្ធិរបស់ប្រធានរដ្ឋបាល")។

[39] កិច្ចព្រមព្រៀងអ.វ.ត.ក មាត្រា៧(៤)។ ច្បាប់អ.វ.ត.ក មាត្រា២៣ថ្មី។ វិធាន៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។ *សូមមើលបន្ថែមទៀត* ឯកសារ **D1/1.3** ការពិចារណារបស់ អ.ប.ជ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៣។

[40] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* ផ្នែកសម្រេចសេចក្តី EN 01634239 (ជាឯកច្ឆ័ន្ទ)។ *សូមមើលបន្ថែមទៀត* សំណុំរឿង០០៤/២-ឯកសារ **D359/24** &

សម្រេចថា មានតែផ្លូវពីរទេដែលស្របច្បាប់សម្រាប់ ស.ច.ស ពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារបស់ពួកគាត់ គឺ៖ (i) ឈានទៅការឯកភាពគ្នាជាប្រយោល ឬដោយផ្ទាល់ទៅលើដីកាដំណោះស្រាយតែមួយគត់ ឬ (ii) បញ្ជូនការខ្វែងយោបល់គ្នាទៅកាន់ អ.ប.ជ តាមយន្តការផ្លូវការនៃការខ្វែងយោបល់គ្នា នៅក្នុងមាត្រា៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា២៣ថ្មី នៃច្បាប់ អ.វ.ត.ក និង វិធាន៧២ នៃវិធានផ្ទៃក្នុង[41]។ តាមរយៈការព្រមព្រៀងគ្នាចេញដីកាដំណោះស្រាយខ្វែងគ្នានេះ អ.ប.ជ បានសន្និដ្ឋានថា ស.ច.ស បានប្រព្រឹត្តកំហុសផ្នែកច្បាប់ និងខកខានមិនបានប្រើប្រាស់ឲ្យបានល្អិតល្អន់នូវនីតិវិធីចាំបាច់ ដើម្បីដោះស្រាយការខ្វែងយោបល់គ្នារបស់ខ្លួន[42]។

27. ដោយពិចារណាអំពីការសម្រេចដ៏ច្បាស់លាស់នេះមក ស.ព.អ មិនជំទាស់ទៅនឹងទិដ្ឋភាពនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរនេះទេ[43] ប៉ុន្តែ ឆ្លើយតបទៅនឹងសារណារបស់ យឹម ទិត្យ ពាក់ព័ន្ធនឹងផលប៉ះពាល់នៃកំហុសនេះលើស្ថានភាពផ្លូវច្បាប់នៃដីកាដំណោះស្រាយនីមួយៗ។ ចំពោះហេតុផលនានាដូចមានបង្ហាញខាងក្រោមនេះ យឹម ទិត្យ បានបកស្រាយខុសអំពីផលវិបាកទាំងអស់នេះ។

### ក. អ.ប.ជ មិនត្រូវបានតម្រូវឲ្យបដិសេធដីកាដំណោះស្រាយទាំងពីរនេះទេ

28. ដំណោះស្រាយដែលបានស្នើឡើងដោយ យឹម ទិត្យ ដែលតម្រូវឲ្យបដិសេធដីកាដំណោះស្រាយទាំងពីរ[44] គឺពុំមានអង្គសេចក្តីនោះទេ ហើយវានៅតែបើកចំហរឲ្យ អ.ប.ជ បដិសេធតែដីកាដំណោះស្រាយមួយប៉ុណ្ណោះ។ ការណ៍នេះត្រូវបានបង្ហាញជាដំបូង និងសំខាន់បំផុត ដោយសេចក្តីពិចារណារបស់ អ.ប.ជ នៅក្នុងសំណុំរឿង០០៤/២។ បន្ទាប់ពីការកំណត់ជាឯកច្ឆ័ន្ទថា *ការចេញ*

---

**D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៥៤, ៨៩, ១០២, ១២០-១២៤ (ជាឯកច្ឆ័ន្ទ)។

[41] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១០៣-១២៤ ជាពិសេសកថាខណ្ឌ ១២០ (ជាឯកច្ឆ័ន្ទ)។

[42] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៥៤, ៨៨-១២៤ (ជាឯកច្ឆ័ន្ទ)។

[43] ឯកសារ **D381/18** & **D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ២១-៣៦។

[44] ឯកសារ **D381/18** & **D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ១, ៣៧-៤០, និង EN 01631777 (ដំណោះស្រាយ)។

ដីកាដំណោះស្រាយពីរខ្វែងគ្នានេះខុសច្បាប់[45] បន្ទាប់មកចៅក្រមមិនបានបដិសេធដីកាដំណោះស្រាយនៃសំណុំរឿង០០៤/២ ទាំងពីរនេះទេ។ ផ្ទុយទៅវិញ ពួកគាត់បានពិចារណាអំពីនីត្យានុកូលភាពនៃដីកាដំណោះស្រាយ*នីមួយៗ* បានឈានដល់សេចក្តីសន្និដ្ឋានផ្សេងគ្នាលើឋានៈផ្លូវច្បាប់ដាច់ដោយឡែកពីគ្នានៃដីកាទាំងអស់នោះ[46]។

29. តាមពិត អំណះអំណាងជាមូលដ្ឋានរបស់ យឹម ទិត្យ ដែលថា ស.ច.ស ត្រូវបានតម្រូវឱ្យចេញដីកាដំណោះស្រាយរួមគ្នាមួយ និងមិនត្រូវបានអនុញ្ញាតឱ្យបំពេញកិច្ចតែម្នាក់ឯង[47] បានមើលរំលងថា អ.ប.ជ ធ្លាប់បានបញ្ជាក់ជាដដែលៗ និងជាឯកច្ឆ័ន្ទថា ស.ច.ស មិនត្រូវបានតម្រូវឱ្យចេញដីកាសម្រេចរួមនោះទេ។ អង្គជំនុំជម្រះនេះធ្លាប់បានទទួលស្គាល់ថា ជាគោលការណ៍ ស.ច.ស តែម្នាក់អាចបំពេញកិច្ចតែម្នាក់ឯងយ៉ាងមានសុពលភាព ជាពិសេស ក្នុងករណីដែលសហការីរបស់គាត់បានដកខ្លួនចេញពីការបន្តការស៊ើបអង្កេត[48]។ អ.ប.ជ ធ្លាប់បានសម្រេចថា "វិធាន ចែងថា [កិច្ចព្រមព្រៀង ច្បាប់អ.វ.ត.ក និង វិធានផ្ទៃក្នុង] សហចៅក្រមស៊ើបអង្កេតម្នាក់អាចបំពេញកិច្ចតែម្នាក់ឯង ជាពិសេសនៅក្នុងករណីដែល សហការីរបស់គាត់បានដកខ្លួនចេញពីការបន្តកិច្ចស៊ើបសួរ"[49] ដោយបានបន្ថែមថា "ក្របខណ្ឌច្បាប់បច្ចុប្បន្ន [របស់ អ.វ.ត.ក] មាន

---

[45] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៥៤, ៨៩, ៩៨, ១០២, ១២៤ ផ្នែកសម្រេចសេចក្តី EN 01634239 (ជាឯកច្ឆ័ន្ទ)។

[46] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៨៩, ១២៤ (ជាឯកច្ឆ័ន្ទ) កថាខណ្ឌ ១៧០-៣០២ (យោបល់របស់ចៅក្រមជាតិ) កថាខណ្ឌ ៣០៤-៣២៩, ៦៨១ (យោបល់របស់ចៅក្រមអន្តរជាតិ)។

[47] ឯកសារ **D381/18 & D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ២៥-២៦, ២៨, ៣៤, ៣៨-៤០។

[48] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១០៥ (ជាឯកច្ឆ័ន្ទ) *ដោយបានលើកឡើងពី* ឯកសារ **D236/1/1/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិសុំពិចារណាឡើងវិញ និងលុបចោលដីកាកោះ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងញត្តិរបស់ អ៊ឹម ចែម") កថាខណ្ឌ ៣០។ ឯកសារ **A122/6.1/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំឮ្យការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤ ("សេចក្តីសម្រេចលើសំណើសុំព្យួរការកោះហៅ អ៊ឹម ចែម") កថាខណ្ឌ ១៤។

[49] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១០៥ (ជាឯកច្ឆ័ន្ទ) *ដោយបានលើកឡើងពី* ឯកសារ **D208/1/1/2** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ស្តីពី

ប្រព័ន្ធត្រួតពិនិត្យគ្រប់គ្រាន់ ដើម្បីធានាថា សកម្មភាពជាឯកតោភាគីត្រូវបានធ្វើឡើងអនុលោមទៅតាមច្បាប់"[50]។

## ខ. មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះអាចត្រូវបានតម្កល់តាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក

30. តាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ដូចដែលត្រូវបានបញ្ជាក់នាពេលថ្មីៗនេះ នៅក្នុងសេចក្ដីពិចារណាលើសំណុំរឿង០០៤/២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង ដីកាសម្រេចលើកលែងចោទប្រកាន់នៃសំណុំរឿង០០៤ មិនស្មើគ្នាទេ នៅក្នុងការគោរពរបស់ខ្លួនតាមច្បាប់នីតិវិធីជាធរមាន។ ការណ៍នេះដោយហេតុថា ទោះបីជា ស.ច.ស មិនបានអនុវត្តតាមជម្រើសណាមួយក្នុងចំណោមជម្រើសទាំងពីរដែល អ.ប.ជ បញ្ជាក់ថាពួកគាត់មាននៅ ពេលពួកគាត់មិនអាចឯកភាពគ្នាបានថាតើត្រូវចោទប្រកាន់[51] ឬយ៉ាងណានោះ គឺមានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះត្រូវបានចេញស្របតាមគោលជំហរស្វ័យប្រវត្តិ "ជាមូលដ្ឋាន និង ជាកត្តាកំណត់" ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"[52]។ គោលជំហរស្វ័យប្រវត្តិនេះត្រូវអនុវត្ត លើកលែងតែចៅក្រម ឬចៅក្រមណាម្នាក់ក្នុងចំណោមពួកគាត់នៅក្នុងរយៈពេល ៣០ថ្ងៃ នៃការចុះកំណត់ហេតុខ្វែងយោបល់គ្នានេះ ស្នើសុំថាការខ្វែងយោបល់គ្នានេះត្រូវដោះស្រាយដោយ អ.ប.ជ[53]។ នៅក្នុងករណីនេះ មិនមាន ស.ច.ស ណាម្នាក់បានបញ្ជូន

---

ការខ្វែងយោបល់គ្នា កថាខណ្ឌ ១១។ ឯកសារ **A122/6.1/3** សេចក្ដីសម្រេចលើសំណើសុំឲ្យរការកោះហៅ អ៊ឹម ចែម កថាខណ្ឌ ១៤។ ឯកសារ **D236/1/1/8** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងញត្តិរបស់ អ៊ឹម ចែម កថាខណ្ឌ ២៤។ សំណុំរឿង០០៣-ឯកសារ **D128/1/9** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការចោទប្រកាន់ក្នុងសំណុំរឿង០០៣ កថាខណ្ឌ ៣៤។

[50] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១០៥ (ជាឯកច្ឆ័ន្ទ) *ដោយបានលើកឡើងពី* ឯកសារ **D236/1/1/8** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងញត្តិរបស់ អ៊ឹម ចែម កថាខណ្ឌ ៣១។ សំណុំរឿង០០៣-ឯកសារ **D128/1/9** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការចោទប្រកាន់ក្នុងសំណុំរឿង០០៣ កថាខណ្ឌ ៣៤។

[51] *សូមមើល ខាងលើ* កថាខណ្ឌ ២៦។

[52] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១០៦-១០៧, ១១១-១១២, ១១៦-១១៧ (ជាឯកច្ឆ័ន្ទ)។

[53] កិច្ចព្រមព្រៀងអ.វ.ត.ក មាត្រា៥(៤)។ ច្បាប់អ.វ.ត.ក មាត្រា២៣ថ្មី។ សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១០៦-១០៧, ១១១-១១២, ១១៦-១១៧ (ជាឯកច្ឆ័ន្ទ)។

បញ្ហានៃការខ្វែងយោបល់គ្នានេះទៅ អ.ប.ជ នៅក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ នេះទេ[54]។

31. នៅក្នុងស្ថានភាពជាក់លាក់នេះ កាលណា ស.ច.ស ណាម្នាក់ក្នុងចំណោម ស.ច.ស ទាំងពីរ ស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយ ស.ច.ស ម្នាក់ផ្សេងទៀតមិនយល់ស្របតាម អត្ថន័យច្បាស់លាស់បំផុតនៃ "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត" នោះគឺថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែចេញដូចដែលបានស្នើឡើង ហើយហេតុដូច្នេះ ត្រូវបានទទួលយកដោយ អ.ជ.ស.ដ[55]។ មិនមានការបកស្រាយសមហេតុសមផលណាមួយនៃលក្ខខណ្ឌដែលថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត" នោះអាចរួមបញ្ចូលការចេញដីកាសម្រេចលើកលែងចោទប្រកាន់ ជំនួសឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ ផ្ទុយទៅនឹងគោលជំហរស្វ័យប្រវត្តិ ដីកាសម្រេចលើកលែងចោទប្រកាន់ រារាំងការស៊ើបអង្កេតមិនឱ្យដំណើរការទៅមុខទៀត។ ម្យ៉ាងវិញទៀត ដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុញ្ញាតឱ្យមានដំណើរការតុលាការបន្តទៅដល់ដំណាក់កាលបន្ទាប់ទៀតនៃកិច្ចដំណើរការនីតិវិធី គឺថា ទៅជនុះជម្រះ។ ការបកស្រាយនេះត្រូវបានគាំទ្រដោយសេចក្តីសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ នៅក្នុងសំណុំរឿង០០២។

32. នៅក្នុងសំណុំរឿង០០២ ស.ច.ស មិនបានឯកភាពគ្នាលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ជនត្រូវចោទបួនរូប ចំពោះឧក្រិដ្ឋកម្មថ្នាក់ជាតិនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។ ដោយយល់ឃើញថាខ្លួនស្ថិតនៅក្នុង "*ភាពទាល់ច្រកនៃកិច្ចដំណើរការនីតិវិធី*" ប៉ុន្តែយល់ឃើញថា ការបញ្ជូនការខ្វែងយោបល់គ្នានេះទៅ អ.ប.ជ តាមវិធាន៧២ នៃវិធានផ្ទៃក្នុង នឹងបណ្តាលឱ្យមានការពន្យារពេលមិនចាំបាច់[56] ស.ច.ស ទាំងពីររូបរួមគ្នាបង្គាប់ថា ជនត្រូវចោទត្រូវ*បានចោទប្រកាន់* និងបញ្ជូនទៅចំពោះមុខ អ.ជ.ស.ដ ចំពោះបទចោទប្រកាន់ទាំងនោះ[57]។ ក្រោយពីពិនិត្យឡើងវិញ អ.ប.ជ បានសម្រេចថា គោលជំហរស្វ័យប្រវត្តិ ដែលថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត" គឺ

---

[54] *សូមមើល*ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២១។ *សូមមើលបន្ថែមទៀត* ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៣។

[55] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៣២២-៣២៣ (យោបល់របស់ចៅក្រមអន្តរជាតិ)។

[56] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ("ដីកាដំណោះស្រាយលើសំណុំរឿង ០០២") កថាខណ្ឌ ១៥៧៤។

[57] សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយលើសំណុំរឿង០០២ កថាខណ្ឌ ១៥៧៦។

"ស្របទៅនឹងវិធីសាស្ត្រ ដែលសហចៅក្រមស៊ើបអង្កេតបានយកមកអនុវត្តនៅក្នុងករណីបច្ចុប្បន្ននេះ"[58] អ.ប.ជ បានបញ្ជាក់លើការសម្រេចនេះជាឯកច្ឆ័ន្ទនៅក្នុងសេចក្តីពិចារណារបស់ខ្លួនលើសំណុំរឿង០០៤/២ នាពេលថ្មីៗនេះ[59]។ ការណ៍នេះមានន័យថា កាលណាមានការខ្វែងយោបល់គ្នារវាង ស.ច.ស គឺមានតែដីកាសម្រេចចោទប្រកាន់ និងបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ដែលស្របគ្នាទៅនឹងគោលជំហរស្វ័យប្រវត្តិ ដែលថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"។

33. ស្រដៀងគ្នានេះដែរ នៅក្នុងសាលដីកានៃសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូល "អ.ជ.ត.ក" បានសម្រេចថា៖

> ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬ ក្នុងការស្នើឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬ មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើ អង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[60]។

ការបកស្រាយដ៏សមហេតុសមផលតែមួយគត់នៃសេចក្តីសម្រេចនេះ គឺថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញដោយ ស.ច.ស តែម្នាក់ឯង នឹងត្រូវបន្តទៅជំនុំជម្រះ - វាមិនមានន័យផ្សេងណាមួយដែលនៅក្នុងនោះអ្វីមួយអាច "បន្ត" នៅក្នុងដំណាក់កាលដែល អ.ជ.ត.ក កំពុងពិភាក្សានេះទេ *គឺ* នៅពេលដែលការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់កំពុងត្រូវបានស្នើឡើង។ ដោយហេតុថាវិធាននៃផ្ទៃក្នុងកំណត់និយមន័យ "ដំណាក់កាលជំនុំជម្រះ" ថាជាការ "សំដៅទៅលើកាលបរិច្ឆេទចាប់ផ្តើមពីពេលដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង"[61] អ.ជ.ត.ក ក៏ទំនងជាពិចារណាផងដែរថា "ការស៊ើបអង្កេត" បន្តរហូត

---

[58] សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៤ (ការសង្កត់ន័យត្រូវបានបន្ថែម)។

[59] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១០៦ (ជាឯកច្ឆ័ន្ទ)។ *សូមមើលផងដែរ* កថាខណ្ឌ ១១៤-១១៥។

[60] សំណុំរឿង០០១-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីការបស់*ឌុច*") កថាខណ្ឌ ៦៥ *ដោយបានលើកឡើងពី* ច្បាប់អ.វ.ត.ក មាត្រា២៣ថ្មី។ កិច្ចព្រមព្រៀងអ.វ.ត.ក មាត្រា៧(៤)។ វិធាន៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

[61] វិធានផ្ទៃក្នុង ទំព័រ៨៥។

ដល់ពេលដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះបានក្លាយទៅជាស្ថាពរ ដែលបន្ទាប់ពីនោះ "ដំណាក់កាលជំនុំជម្រះ" ចាប់ផ្តើម។

34. ជាងនេះទៅទៀត មានតែការបកស្រាយនេះប៉ុណ្ណោះដែលស្របគ្នាទៅនឹងច្បាប់ជាតិ និងអន្តរជាតិ ជាធរមាននៅ អ.វ.ត.ក ដែលតម្រូវថា កិច្ចប្រឹងប្រែងក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ខ្លួន មានលក្ខណៈពិតប្រាកដ និងថា ស្ថាប័ន អ.វ.ត.ក ធានាឲ្យមានការស៊ើបអង្កេតដ៏មានប្រសិទ្ធិភាព និងផ្តន្ទាទោសឧក្រិដ្ឋកម្មនានា[62]។ សេចក្តីសន្និដ្ឋាននេះ គឺត្រូវបានគាំទ្របន្ថែមទៀតដោយកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក[63] ដែលត្រូវ "*កាត់សេចក្តី* មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[64]។ វាក៏ស្របគ្នាផងដែរជាមួយនឹងកម្មវត្ថុនៃ

---

[62] សំណុំរឿង០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១១០ (ជាឯកជ្ជ័ន្ទ)។

[63] អនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ 1155 UNTS 331 មាត្រា៣១(១) ("សន្ធិសញ្ញាត្រូវបានបកស្រាយដោយសុទ្ធចិត្ត ឲ្យត្រូវទៅតាមន័យធម្មតាដែលត្រូវបានផ្តល់ឲ្យពាក្យពេចន៍នៃសន្ធិសញ្ញានៅក្នុងបរិបទរបស់វា និងដោយគិតទៅដល់កម្មវត្ថុ និងគោលបំណងរបស់វា")។ *សូមមើលផងដែរ ឧទាហរណ៍ ច្បាប់រដ្ឋធម្មនុញ្ញរបស់គណៈកម្មាធិការសុវត្ថិភាពសមុទ្រនៃអង្គការអន្តររដ្ឋាភិបាលពិគ្រោះយោបល់ស្តីពីសមុទ្រ* យោបល់ប្រឹក្សា ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៦០ របាយការណ៍របស់ ICJ ទំព័រ១៥០ ត្រង់១៥៨ ("ពាក្យបានន័យពីបរិបទដែលនៅក្នុងនោះវាត្រូវបានប្រើ")។ *លក្ខខណ្ឌកំណត់ចំពោះអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍* យោបល់ប្រឹក្សា ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៥១ របាយការណ៍របស់ ICJ ឆ្នាំ១៩៥១ ទំព័រ១៥ ត្រង់២៤។ *សិទ្ធិរបស់ជនជាតិសហរដ្ឋអាមេរិកនៅក្នុងប្រទេសម៉ារ៉ុក (ប្រទេសបារាំង ទល់នឹង សហរដ្ឋ)* សាលក្រម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៥២ របាយការណ៍របស់ ICJ ឆ្នាំ១៩៥២ ទំព័រ១៧៦ ត្រង់១៩៦។ *សូមមើលបន្ថែមទៀត ឧទារណ៍ ករណី ឆកសមុទ្រ Corfu (ប្រទេសចក្រភពអង់គ្លេស ទល់នឹង ប្រទេសអាល់បានី)* សាលក្រម ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៤៩ របាយការណ៍របស់ ICJ ឆ្នាំ១៩៤៩ ទំព័រ៤ ត្រង់២៤ ("តាមពិត វាត្រូវតែមានវិសមិតភាពជាមួយនឹងវិធានដែលគេទទួលស្គាល់ជាទូទៅស្តីពីការបកស្រាយដើម្បីទទួលយកនូវបទប្បញ្ញត្តិរបៀបនេះ ដែលកើតឡើងនៅក្នុងកិច្ចព្រមព្រៀងជាក់លាក់មួយដែលគួរតែគ្មានបានការអំពីសេចក្តីអះអាង ឬប្រសិទ្ធិភាព")។ *សំណងជួសជុលចំពោះការត្រូវរបួសដែលបានរងគ្រោះនៅក្នុងការបំពេញបេសកកម្មរបស់អង្គការសហប្រជាជាតិ* (យោបល់ប្រឹក្សា) ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៤៩ របាយការណ៍របស់ ICJ ឆ្នាំ១៩៤៩ ទំព័រ១៧៤ ត្រង់១៧៩ ហើយនឹងមួយតទៅទៀត (ដោយយល់ឃើញស្ថានភាពជាក់លាក់មួយ និងសមត្ថកិច្ចរបស់អង្គការ អ.ស.ប ពីអង្គហេតុដែលថា បើគ្មានពួកវាទេ វាមិនអាចបំពេញមុខងារដែលវាច្បាស់ជាមានបំណងចង់បាន)។ *ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ប្រទេស Georgia ទល់នឹង សហភាពរុស្ស៊ី)* អញ្ញត្រកម្ម សាលក្រម ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ របាយការណ៍របស់ ICJ ឆ្នាំ២០១១ ទំព័រ៧០ កថាខណ្ឌ ១៣៣-១៣៤។

[64] កិច្ចព្រមព្រៀងអ.វ.ត.ក មាត្រា១ (ការសង្កត់ន័យត្រូវបានបន្ថែម)។ ច្បាប់អ.វ.ត.ក មាត្រា១ (ការសង្កត់ន័យត្រូវបានបន្ថែម)។

យន្តការដោះស្រាយការខ្វែងយោបល់គ្នា ដែលត្រូវ "រារាំងការជាប់គាំង ដែលធ្វើឲ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ"[65]។

35. តាមពិត តាមវិធីដូចគ្នានេះ អ.ប.ជ បានបញ្ជាក់ជាឯកច្ឆ័ន្ទនៅក្នុងសេចក្តីពិចារណារបស់ខ្លួន ពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា លើបញ្ហាថាតើត្រូវបញ្ជូនសំណុំរឿង០០៣ និង ០០៤ ទៅ ស.ច.ស ឬយ៉ាងណានោះ ថា ចំពោះឃ្លា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"[66] ដែលមានន័យថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ជាឯកសារដែលនាំឲ្យចាប់ផ្តើមការស៊ើបអង្កេតនេះ ហើយដែលបានកំណត់វិសាលភាពរបស់ខ្លួននេះ[67] គួរត្រូវបញ្ជូនទៅឲ្យ ស.ច.ស[68]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ស្របគ្នាទៅនឹងគោលជំហរស្វ័យប្រវត្តិនេះ "សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ក្រោយពីការផ្តល់ឲ្យរយៈពេលសាមសិបថ្ងៃតាមការជូនដំណឹងដល់សហព្រះរាជអាជ្ញាជាតិ ប្រសិនបើការខ្វែងយោបល់គ្នាមិនត្រូវបានបញ្ជូនមកនៅចំពោះមុខអង្គបុរេជំនុំជម្រះទេនោះ"[69]។ នៅក្នុងសេចក្តីពិចារណារបស់ខ្លួនលើសំណុំរឿង០០៤/២ នាពេលថ្មីៗនេះ អង្គជំនុំជម្រះនេះបានគូសបញ្ជាក់ពីភាពស្របគ្នារវាងដីកាសម្រេចនេះ និងគោលជំហរស្វ័យប្រវត្តិដែលអាចអនុវត្តបានចំពោះការខ្វែងយោបល់គ្នារវាង ស.ច.ស[70]។

36. អាស្រ័យហេតុដូច្នេះ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ ដែលត្រូវបន្តសំណុំរឿង០០៤ ទៅកាន់ការជំនុំជម្រះនោះ គឺត្រូវបានធ្វើឡើងស្របគ្នាទាំងស្រុងជាមួយនឹងគោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់ ហើយការខកខានរបស់គាត់មិនប្តឹងទៅ

---

[65] *សូមមើល* សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៣២៣ (យោបល់របស់ចៅក្រមអន្តរជាតិ) និងការលើកឡើងនៅក្នុងនោះ។

[66] កិច្ចព្រមព្រៀងអ.វ.ត.ក មាត្រា៦(៤), ៧(៤)។ ច្បាប់អ.វ.ត.ក មាត្រា២០ថ្មី។

[67] វិធាន៥៣, ៥៥(២) នៃវិធានផ្ទៃក្នុង។

[68] ឯកសារ **D1/1.3** ការពិចារណារបស់ អ.ប.ជ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧, ៤៥ (ដូចដែលបានកែតម្រូវនៅក្នុងឯកសារ **D1/1.2** ការកែតម្រូវលើសេចក្តីដកស្រង់ការពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធានផ្ទៃក្នុង និង ឧបសម្ព័ន្ធII ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩)

[69] ឯកសារ **D1/1.3** ការពិចារណារបស់ អ.ប.ជ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧។

[70] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កំណត់សម្គាល់ជើងទំព័រលេខ ១៨៨ (ជាឯកច្ឆ័ន្ទ)។

អ.ប.ជ នៅក្រោមយន្តការនៃការខ្វែងយោបល់គ្នាជាផ្លូវការ មិនធ្វើឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះអស់សុពលភាពនោះទេ។

37. ផ្ទុយទៅវិញ ការចេញដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ ដែលបានស្នើឡើង - បើពុំនោះសោតទេ ត្រូវបានចាត់ទុកថាជាការខ្វែងយោបល់គ្នាទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ[71] - បានចាប់ផ្តើមកាតព្វកិច្ចរបស់គាត់ ឱ្យបញ្ជូនបញ្ហានេះទៅកាន់ អ.ប.ជ បើសិនជាគាត់មិនយល់ស្របជាមួយនឹងដំណើរការប្រព្រឹត្តទៅ ដែលវាមានលក្ខណៈ "ជាប់ទងគ្នា" ជាមួយនឹងគោលជំហរស្វ័យប្រវត្តិ ជាប់ជាមួយនឹងក្របខណ្ឌច្បាប់ អ.វ.ត.ក[72]។ អ.ប.ជ ធ្លាប់បានពន្យល់ថា កាលណាការខ្វែងយោបល់គ្នាមានលក្ខណៈសំខាន់ខ្លាំង ដែល ស.ច.ស ម្នាក់ ចង់បញ្ឈប់ការអនុវត្តដីកាសម្រេចរបស់សហការីរបស់ខ្លួន នោះជម្រើសផ្លូវច្បាប់តែមួយគត់របស់ ស.ច.ស គឺត្រូវបញ្ជូនការខ្វែងយោបល់គ្នានេះទៅចំពោះមុខ អ.ប.ជ[73]។ ប៉ុន្តែ ស.ច.ស.ជ បាន ខកខានក្នុងការធ្វើតាមវិធានការជាកាតព្វកិច្ចដែលតម្រូវនេះ ដើម្បីតវ៉ាតាមផ្លូវច្បាប់អំពីការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូច្នេះហើយ ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានចេញដោយពុំមានមូលដ្ឋានច្បាប់នោះទេ។

---

[71] *សូមមើល* សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៣២៣ (យោបល់របស់ចៅក្រមអន្តរជាតិ) និងការលើកឡើងនៅក្នុងនោះ។ *សូមមើលផងដែរ* ឯកសារ **D1/1.3** ការពិចារណារបស់ អ.ប.ជ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧ ("បញ្ហានេះមិនត្រូវបានគិតទុកជាមុនថា ការខ្វែងយោបល់គ្នាត្រូវបានបញ្ជូនដោយស.ព.អ ដែលបានពន្យល់អំពីការយល់ឃើញរបស់ខ្លួន អំពីមូលហេតុដែលសហព្រះរាជអាជ្ញាជាតិជំទាស់ទៅនឹងការសម្រេចចិត្តរបស់គាត់ ក្នុងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនោះទេ។ [...] បើអនុវត្តតាមនីតិវិធីត្រឹមត្រូវនោះ គឺសហព្រះរាជអាជ្ញាជាតិទេ ដែលជាអ្នកជំទាស់ទៅនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីទាំងនោះ ត្រូវដាក់សារណាជាលាយលក្ខណ៍អក្សររបស់គាត់មុន")។

[72] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១០៦, ១១៤-១១៦ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧៥។

[73] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១១៧, ១១៩-១២០, ១២២ (ជាឯកច្ឆ័ន្ទ)។

38. ស.ព.អ សន្និដ្ឋានថា តាមក្របខណ្ឌច្បាប់នេះ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ គឺស្របគ្នាជាមួយនឹងច្បាប់នីតិវិធីជាធរមាន ដូច្នេះត្រូវតែតម្កល់[74]។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទប្រកាន់របស់ ស.ច.ស.ជ គឺមិនត្រូវបានចេញដោយត្រឹមត្រូវទេ ដូច្នេះ គួរត្រូវបានច្រានចោលដោយឈរលើមូលដ្ឋាននេះតែមួយ[75]។

***ទាំងគោលការណ៍ សច្ចធារណ៍នៃនិរទោស និង គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ ជនជាប់ចោទ មិនរារាំង អ.ប.ជ មិនឱ្យតម្កល់តែដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ***

39. យឹម ទិត្យ ខកខានមិនបានបង្ហាញថា ការតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានចេញដោយ ស.ច.ស រំលោភលើសិទ្ធិរបស់គាត់ចំពោះសច្ចធារណ៍នៃនិរទោសឡើយ[76]។ សច្ចធារណ៍នេះធានាថា មុនពេលដែលការផ្តន្ទាទោសព្រហ្មទណ្ឌអាចត្រូវបានកំណត់ បន្ទុកស្ថិតនៅលើភាគីចោទប្រកាន់ ដើម្បីបង្ហាញភស្តុតាងពីពិរុទ្ធភាពរបស់ជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យ *នៅពេលជំនុំជម្រះ*[77]។ វានៅតែមិនប្រែប្រួល លុះត្រាតែ និងរហូតទាល់តែ យឹម ទិត្យ ត្រូវបានកាត់ឱ្យជាប់ទោសដោយ

---

[74] ចំពោះហេតុផលនានាដែលមានចែងនៅក្នុងចម្លើយតបរបស់ ស.ព.អ ទៅនឹងឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ទៅនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ អំណះអំណាងរបស់ យឹម ទិត្យ អំពីកំហុសអង្គហេតុ និងអង្គច្បាប់ជាដុំកំភួន ក៏ដូចជាការលើកឡើងចោទប្រកាន់របស់គាត់អំពីការរំលោភលើឆន្ទានុសិទ្ធិរបស់ ស.ច.ស.អ នៅក្នុងការចេញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ គឺមិនមានមូលដ្ឋាននោះទេ និង/ឬ មិនមែនជាកត្តាកំណត់ទៅតាមមូលដ្ឋាន នៃការប្រើឆន្ទានុសិទ្ធិរបស់គាត់នៅក្នុងការកំណត់ថា យឹម ទិត្យ ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ *សូមមើល* ឯកសារ **D382/27** ម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

[75] ចំពោះហេតុផលនានាដែលមានចែងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ ដីកាសម្រេចលើកលែងការចោទប្រកាន់នោះក៏មានកំហុសអង្គហេតុ និងអង្គច្បាប់មួយចំនួនផងដែរ ដែលមិនមែនជាកត្តាកំណត់ទៅតាមមូលដ្ឋាននៃការប្រើឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលដែលតម្រូវឱ្យមានការច្រានចោល។ *សូមមើល* ឯកសារ **D381/19** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទ ប្រកាន់ យឹម ទិត្យ (D381) ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់")។

[76] ឯកសារ **D381/18** & **D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ១៦, ៣៤។

[77] *រដ្ឋអាជ្ញា ទល់នឹង Kayishema & Ruzindana*, ICTR-95-1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ (សាលដីកា (សំអាងហេតុ) ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ១០៧។ វិធាន ២១ នៃវិធានផ្ទៃក្នុង។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីការបស់សាលដីកា *ខុច* កថាខណ្ឌ ៣៣។ ច្បាប់ អ.វ.ត.ក មាត្រា ៣៥ ថ្មី។ *សូមមើលបន្ថែមយោងខាងលើ* កថាខណ្ឌ ៤៣។

សំឡេងភាគច្រើនលើសលុបរបស់ចៅក្រម អ.ជ.ស.ដ[78]។ ហេតុដូច្នេះ អាណត្តិរបស់ ស.ច.ស តាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុងធ្វើការស៊ើបអង្កេតដោយអនាគតិដើម្បីបញ្ជាក់ការពិត និងអង្គហេតុដែលថា កិច្ចដំណើរការនីតិវិធីកំពុងស្ថិតនៅក្នុងដំណាក់កាលមុនជំនុំជម្រះនៅឡើយ ដោយមិនមានការសម្រេចអំពីពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធនោះ ផ្ទុយពីអំណះអំណាងរបស់ យឹម ទិត្យ[79]។

40. ជាងនេះទៀត ការអះអាងរបស់ យឹម ទិត្យ ថា ក្នុងករណីខ្វែងយោបល់គ្នាលើបញ្ហាថាតើជនត្រូវចោទស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬអត់ (និងដូច្នេះថាតើត្រូវបញ្ជូនទៅជំនុំជម្រះឬយ៉ាងណានោះ) ស.ច.ស ត្រូវបានតម្រូវឲ្យឯកភាពគ្នាលើអង្គហេតុ បើមិនដូច្នោះទេត្រូវអនុវត្ត *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដើម្បីបដិសេធរឿងក្តី[80] ការអះអាងនេះមើលរំលងច្បាប់ជាធរមាន និងប្រភេទនៃសេចក្តីសម្រេចរបស់ ស.ច.ស។

41. ទីមួយ សម្រាប់មូលហេតុដូចដែលបានបង្ហាញខាងលើនេះ[81] ក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ចែងថា ក្នុងករណីខ្វែងយោបល់គ្នារវាង ស.ច.ស បែបនេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយចៅក្រមតែម្នាក់ មានអធិកភាពក្នុងករណីមិនមានការឯកភាពគ្នារវាង ស.ច.ស ដែលការណ៍នេះស្របគ្នាទៅនឹងគោលជំហរស្វ័យប្រវត្តិដែលថា "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" បើមិនដូច្នេះទេ ត្រូវបញ្ជូនការខ្វែងយោបល់ទៅកាន់ អ.ប.ជ តាមយន្តការខ្វែងយោបល់ផ្លូវការ។ អត្ថិភាពនៃគោលជំហរស្វ័យប្រវត្តិនេះ ផ្ទុយគ្នាទាំងស្រុងទៅនឹងការអះអាងថា បញ្ហាខ្វែងយោបល់ត្រូវតែដោះស្រាយក្នុងប្រយោជន៍ដល់ជនត្រូវចោទជានិច្ច តាមរយៈការលើកលែងចោទប្រកាន់។

42. យឹម ទិត្យ ក៏មើលរំលងថា ការដែលតម្រូវឲ្យ ស.ច.ស ឯកភាពគ្នាលើការរកឃើញអង្គហេតុដែលមិនអាចផ្សះផ្សារបាន នឹងធ្វើឲ្យអន្តរាយជាមូលដ្ឋានដល់ឯករាជ្យភាពតុលាការ[82] ហើយគាត់យល់ខុសអំពីប្រភេទនៃការកំណត់យុត្តាធិការបុគ្គល។ ការណ៍ដែល ស.ច.ស បានធ្វើការសម្រេចលើអង្គហេតុ ពេលធ្វើការកំណត់របស់ខ្លួនលើយុត្តាធិការបុគ្គលនោះ មិនបានធ្វើឲ្យការកំណត់នោះជា

---

[78] វិធាន ៩៨(៤) នៃវិធានផ្ទៃក្នុង។ សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៦៣ (ជាឯកច្ឆ័ន្ទ)។

[79] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៦៣ (ជាឯកច្ឆ័ន្ទ)។

[80] ឯកសារ **D381/18** & **D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ១៦, ៣១-៣៤, ៣៦។

[81] សូមមើល *យោងខាងលើ* កថាខណ្ឌ ២៩-៣៨។

[82] សូមមើល *យោងខាងលើ* កំណត់សំគាល់ជើងទំព័រ ៣៦។

កត្តាខាងអង្គហេតុនោះទេ។ ស្រដៀងគ្នានេះដែរ អង្គហេតុដែលថា ស.ច.ស មិនឯកភាពគ្នាក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលរបស់ខ្លួន *ដោយខ្លួនវាផ្ទាល់* មិនបង្កើតជាមន្ទិលទៅលើការរកឃើញអង្គហេតុជាមូលដ្ឋានរបស់ខ្លួន ឬការកំណត់អំពីយុត្តាធិការបុគ្គលខ្លួនវាឡើយ[83]។

43. ការណ៍នេះដោយសារតែ ការកំណត់របស់ ស.ច.ស អំពីយុត្តាធិការបុគ្គលគឺជាដំណើរការច្រើនដំណាក់កាល ដោយដំណាក់កាលនីមួយៗមានលក្ខណៈខុសៗគ្នា។ ទីមួយ ស.ច.ស ទាំងពីរបានធ្វើការកំណត់អង្គហេតុជាច្រើនអំពីតួនាទីរបស់ យឹម ទិត្យ ក្នុងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរយៈកាលកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មក និងផ្អែកលើមូលដ្ឋាននៃការរកឃើញអង្គហេតុទាំងនោះ (ដូចដែលត្រូវបានចាត់ថ្នាក់តាមច្បាប់) ទើប ស.ច.ស ត្រូវបានតម្រូវឱ្យអនុវត្ត*ឆន្ទានុសិទ្ធិ*ដាច់ដោយឡែក និងឯករាជ្យរបស់ខ្លួន អំពីថាតើ យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬអត់[84]។ គ្រាន់តែមតិភាគច្រើន និងមតិភាគតិចនៅក្នុងសាលក្រមមួយមិនបណ្តាលឱ្យមានមន្ទិលផ្នែកអង្គហេតុលើមតិយោបល់ទាំងអស់នោះ ឬសាលក្រមនោះទេ អង្គហេតុដែលថា ស.ច.ស ម្នាក់អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនលើបញ្ហាយុត្តាធិការបុគ្គលលំអៀងទៅរកការលើកលែងចោទប្រកាន់ ហើយ ស.ច.ស ម្នាក់ទៀតលំអៀងទៅរកការបញ្ជូនខ្លួនទៅជំនុំជម្រះនោះ *ដោយខ្លួនវាផ្ទាល់* មិនបង្កើតបានជាមន្ទិលផ្នែកអង្គហេតុ ឬតាមពិតនោះជាមន្ទិលណាមួយអំពីការរកឃើញអង្គហេតុជាមូលដ្ឋាន ឬបញ្ហាយុត្តាធិការបុគ្គលនោះទេ។ ការណ៍នេះច្បាស់លាស់ណាស់ថា មូលហេតុដែលលទ្ធផលមួយនៃការខ្វែងយោបល់គ្នាជាផ្លូវការដែលអាចមាន បានមកដល់ចំពោះមុខ អ.ប.ជ គឺថា អង្គជំនុំជម្រះនេះអាចសម្រេចថា មិនមានចៅក្រមណាម្នាក់មានកំហុស

---

[83] *ផ្ទុយពីនេះ* ឯកសារ **D381/18 & D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ១៦, ៣១។ ស.ព.អ ចោទប្រកាន់ដាច់ដោយឡែកពីគ្នាអំពីកំហុសអង្គហេតុ (និងអង្គច្បាប់) ដែលគាត់យល់ថាមានផលប៉ះពាល់ដែលជាការកំណត់លើការកំណត់អំពីយុត្តាធិការបុគ្គលរបស់ដីកាដំណោះស្រាយ។ *សូមមើល* ឯកសារ **D381/19** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់។

[84] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ២៨ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណា របស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់*អ៊ឹម ចែម* កថាខណ្ឌ ២០ (ជាឯកច្ឆ័ន្ទ)។ សំណុំរឿង០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦២-៧៥។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ (“ដីកាដំណោះស្រាយលើសំណុំរឿង០០៤/១”) កថាខណ្ឌ ៩។

ក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់នោះទេ គឺដូចគ្នាទៅនឹង អ.ជ.ត.ក ដែលបានព្យាករក្នុងសំណុំរឿង ០០១[85]ដែរ។

44. ទោះជាយ៉ាងណា *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដូចដែល យឹម ទិត្យ បានអះអាង មិនអនុវត្តលើការរកឃើញអង្គហេតុនៅដំណាក់កាលមុនជំនុំជម្រះទេ[86]។ ផ្ទុយទៅវិញ ដូចដែល យឹម ទិត្យ ទទួលស្គាល់[87] *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាវិបាកនៃសច្ចធារណ៍នៃនិរទោស ហើយវាគឺជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវដែលថា ពិរុទ្ធភាពត្រូវតែរកឃើញ*នៅពេលជំនុំជម្រះ*ឱ្យហួសពីវិមតិសង្ស័យ[88]។ នេះមិនមែនជាបទដ្ឋាននៃភ័ស្តុតាងដែលអាចអនុវត្តបាននៅដំណាក់កាលមុនជំនុំជម្រះឡើយ។ អ.ប.ជ បាន

---

[85] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៥។

[86] ឯកសារ **D381/18** & **D382/21** បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ៣១-៣៦ ជាពិសេស កថាខណ្ឌ ៣៣។

[87] ឯកសារ **D381/18** & **D382/21** បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ៣៣។

[88] សំណុំរឿង ០០២-ឯកសារ **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០១១ ("សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែង ខៀវ សំផន") កថាខណ្ឌ ៣១ ("[អ.ជ.ត.ក] បញ្ជាក់យ៉ាងមុតមាំថា គោលការណ៍ [*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*] នេះ ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលកើតចេញពីគោលការណ៍សន្មត់ទុកជាមុនថាគ្មានទោស")។ *Limaj និងគូកន* IT-03-66-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ២១ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពេញចិត្តថា គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជាវិបាកនៃសច្ចធារណ៍នៃនិរទោស និងបន្ទុកបង្ហាញភ័ស្តុតាងឱ្យហួសពីវិមតិសង្ស័យ អនុវត្តចំពោះការសន្និដ្ឋាននានាដែលត្រូវការសម្រាប់ការកាត់ឱ្យជាប់ទោស ដូចជាការសន្និដ្ឋានទាំងឡាយដែលបង្កើតបានជាធាតុផ្សំនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ [...] គោលការណ៍នេះគ្រាន់តែជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវដែលថា ពិរុទ្ធភាពត្រូវបានរកឃើញឱ្យហួសពីវិមតិសង្ស័យតែប៉ុណ្ណោះ។")។ *Renzaho,* ICTR-97-31-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤៧៤ ("គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ចែងថាការសង្ស័យណាមួយគួរតែត្រូវបានដោះស្រាយជាប្រយោជន៍ដល់ជនជាប់ចោត។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍រំលឹកថាក្នុងនាមជាផលវិបាកនៃសច្ចធារណ៍នៃនិរទោស និងបន្ទុកនៃការបង្ហាញភ័ស្តុតាងឱ្យហួសពីវិមតិសង្ស័យ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អនុវត្តទៅលើការរកឃើញនានាដែលត្រូវបានតម្រូវសម្រាប់ការផ្តន្ទាទោស ដូចជាការរកឃើញទាំងឡាយដែលបង្កើតបានជាធាតុផ្សំនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់")។ (ការដកស្រង់ខាងក្នុងត្រូវបានលុប))។ *សូមមើលផងដែរ* *Delalić និងគូកន.*, IT-96-21-T, អង្គជំនុំជម្រះសាលាដំបូង សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ("សាលក្រម *Čelebići*"), កថាខណ្ឌ៦០១ ("អយ្យការជាប់កាតព្វកិច្ចតាមច្បាប់ត្រូវបង្ហាញភ័ស្តុតាងរឿងក្ដីដែលចោទប្រកាន់ ប្រឆាំងនឹងជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យ។ នៅពេលបិទបញ្ចប់រឿងក្ដី ជនជាប់ចោទមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពីការសង្ស័យចំពោះថាតើ បទល្មើសត្រូវបានបញ្ជាក់ភ័ស្តុតាង ឬទេ")។

សម្រេចយ៉ាងស៊ីចង្វាក់ថា ស្របតាមវិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង បទដ្ឋានដែលត្រូវបំពេញសម្រាប់ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺ "ភ័ស្តុតាងគ្រប់គ្រាន់" នៃបទចោទ[89]។ អង្គជំនុំជម្រះនេះបានបង្កើតឃ្លា "ភ័ស្តុតាងគ្រប់គ្រាន់" ឲ្យមានន័យថា "ភវនីយភាព" ឬ "ភាពអាចជឿជាក់បាន" នៃពិរុទ្ធភាព[90] ដែលជាបទដ្ឋានមួយ មានកម្រិតទាបជាង "ហួសពីវិមតិសង្ស័យ"[91] ដោយសារតែការកំណត់នៅ "ដំណាក់កាលមុនជំនុំជម្រះ [...] មិនពាក់ព័ន្ធនឹងការកំណត់ថាមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនោះទេ"[92]។

45. តាមពិតនោះ មិនមានប្រភពណាដែលបានដកស្រង់ដោយ យឹម ទិត្យ គាំទ្រការអះអាងរបស់គាត់ឡើយ។ មានប្រភពពីរទាក់ទងនឹងការអនុវត្ត *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នៅដំណាក់កាលជំនុំជម្រះ[93]។ ប្រភពពីរទៀតទាក់ទងទៅនឹងការរកឃើញផ្នែកច្បាប់ជាសារធាតុរបស់ អ.ប.ជ[94] ដែលទោះជាយ៉ាងណា ត្រូវបានបដិសេធដោយ

---

[89] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៨៤។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណា របស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់*អ៊ឹម ចែម* កថាខណ្ឌ ៦១ (ជាឯកច្ឆន្ទ)។

[90] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៨៤-៨៥ (ជាឯកច្ឆន្ទ) *និងការដកស្រង់ខាងក្នុង*។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណា របស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់*អ៊ឹម ចែម* កថាខណ្ឌ ៦១-៦២ (ជាឯកច្ឆន្ទ)។

[91] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៨៤-៨៥ (ជាឯកច្ឆន្ទ)។ សំណុំរឿង០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណា របស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់*អ៊ឹម ចែម* កថាខណ្ឌ ៦១-៦២ (ជាឯកច្ឆន្ទ)។ សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយសំណុំរឿង០០២ កថាខណ្ឌ ១៣២៣។

[92] សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ១៦៣ (ជាឯកច្ឆន្ទ)។ *សូមមើលផងដែរ* សំណុំរឿង០០៤/២-ឯកសារ **D359/24 & D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន* កថាខណ្ឌ ៨៥ (ជាឯកច្ឆន្ទ)។ សំណុំរឿង០០២-ឯកសារ **D427** ដីកាដំណោះស្រាយសំណុំរឿង ០០២ កថាខណ្ឌ ១៣២៣។

[93] ឯកសារ **D381/18 & D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ ជើងទំព័រ ៣២ *ដែលបានដកស្រង់* សំណុំរឿង០០២-ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ២១, ៣០១៤។ សំណុំរឿង០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៤ កថាខណ្ឌ ២២។

[94] ឯកសារ **D381/18 & D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ ជើងទំព័រ ៣៤ *ដែលបានដកស្រង់* សំណុំរឿង០០២-ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹង ដីកាដំណោះស្រាយ កថាខណ្ឌ៣១០។ សំណុំរឿង០០២-ឯកសារ **D427/2/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ

អ.ជ.ស.ដ[95]។ យុត្តិសាស្ត្ររបស់ អ.ជ.ត.ក ដែលត្រូវបានដកស្រង់[96] ផ្តោតលើការបែងចែករវាងការអនុវត្ត *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ទៅលើបញ្ហាអង្គហេតុ មិនមែនបញ្ហាច្បាប់ទេ ដោយមិនបានបញ្ជាក់អំពីដំណាក់កាលកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធឡើយ។ ទោះជាយ៉ាងណា ស.ជ.ត.ក មិនបានអនុវត្តគោលការណ៍នេះទាល់តែសោះនៅក្នុងកាលៈទេសៈនោះ។ ជាចុងក្រោយ យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") ដែល យឹម ទិត្យ ដកស្រង់គឺមិនពាក់ព័ន្ធទៅនឹងបញ្ហានេះទេ[97]។ នៅដំណាក់កាលបញ្ជាក់នេះ អង្គបុរេជំនុំជម្រះនៃតុលាការ ICC ត្រូវតែកំណត់ "ថាតើមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបង្កើតមូលដ្ឋានសំខាន់ៗ ដើម្បីជឿជាក់បានថា បុគ្គលនោះបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលចោទប្រកាន់នីមួយៗនោះឬទេ"[98]។ នៅក្នុងសេចក្តីសម្រេចដូចគ្នាដែល យឹម ទិត្យ ដកស្រង់ អង្គបុរេជំនុំជម្រះនៃតុលាការ ICC បានបញ្ជាក់ថា ចំណុចចាប់ផ្តើមភស្តុតាងជាអប្បរមាសម្រាប់ការបញ្ជាក់បទចោទនៅដំណាក់កាលមុនជំនុំជម្រះ គឺទាបជាងបទដ្ឋាន "ហួសពីវិមតិសង្ស័យ" ដែលអនុវត្តនៅដំណាក់កាលជំនុំជម្រះ[99]។

---

ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៤៤។ សាលដីកាទាំងពីរពាក់ព័ន្ធនឹងបញ្ហាថាតើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានចំណងទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិឬទេ។

[95] សំណុំរឿង០០២-ឯកសារ **E95/8** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ កថាខណ្ឌ៣៣។

[96] ឯកសារ **D381/18 & D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ ជើងទំព័រ ៣២-៣៣ *ដែលបានដកស្រង់* សំណុំរឿង០០២-ឯកសារ-**E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែង ខៀវ សំផន កថាខណ្ឌ ៣១។

[97] ឯកសារ **D381/18 & D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ ជើងទំព័រ៣៤ *ដែលបានដកស្រង់ រដ្ឋអាជ្ញា ទល់នឹង Bemba*, ICC-01/05-01/08-424, អង្គបុរេជំនុំជម្រះ II សាលដីកាអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីបទចោទរបស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba Gombo ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ("សាលដីកាលើការបញ្ជាក់បទចោទក្នុងរឿងក្តី *Bemba*") កថាខណ្ឌ ៣១។

[98] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ("លក្ខន្តិកៈទីក្រុងរ៉ូម"), 2187 UNTS 90, មាត្រា ៦១(៧)។

[99] សាលដីកាលើការបញ្ជាក់បទចោទក្នុងរឿងក្តី *Bemba* កថាខណ្ឌ២៧-២៨ (យោងខាងក្នុងត្រូវបានលុប) ("អ្នកធ្វើច្បាប់លក្ខន្តិកៈនេះបានបង្កើតចំណុចចាប់ផ្តើមអប្បរិមានៃភស្តុតាងកម្រិតខ្ពស់ចំនួនបីខុសៗគ្នា សម្រាប់ដំណាក់កាលនីមួយៗនៃកិច្ចដំណើរការនីតិវិធីតាមមាត្រា ៥៨(១), ៦១(៧) និង ៦៦(៣) នៃលក្ខន្តិកៈ។ ប្រភេទនៃចំណុចចាប់ផ្តើមអប្បរិមានៃភស្តុតាងទាំងអស់នេះផ្អែកលើដំណាក់កាលផ្សេងៗគ្នានៃកិច្ចដំណើរការនីតិវិធី និងក៏ស្របផងដែរទៅនឹងផលប៉ះពាល់ដែលអាចព្យាករជាមុន នៃសេចក្តីសម្រេចពាក់ព័ន្ធលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់បុគ្គលដែលត្រូវបានចោទប្រកាន់។ នៅដំណាក់កាលបច្ចុប្បន្ន

46. អំណះអំណាងបន្ថែមរបស់ យឹម ទិត្យ ទាក់ទងនឹងសិទ្ធិរបស់គាត់អំពីភាពប្រាកដប្រជាផ្លូវច្បាប់[100] ភាពច្របូកច្របល់ទាក់ទងនឹងមូលដ្ឋានបទចោទ[101] និងការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័សដូចដែលគាត់បានចោទប្រកាន់នោះ[102] គឺមានការពាក់ព័ន្ធតែទៅនឹងនីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយពីរប៉ុណ្ណោះ។ តាមស្មារតីនៃការបញ្ជាក់អះអាងជាឯកច្ឆន្ទរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយពីរ គឺជារឿងខុសច្បាប់ និងអំពីភាពប្រាកដប្រជាផ្លូវច្បាប់ដែលបានទាញយកពីការអនុម័តិគោលជំហរស្វ័យប្រវត្តិដែលថា "ការស៊ើបអង្កេតត្រូវបន្ត" នោះ អំណះអំណាងទាំងនេះលែងជាការចាំបាច់ទៀតហើយ។

## គ. ប្រសិនបើ អ.ប.ជ ខកខានមិនអាចឈានដល់ការសម្រេចដែលមានសំឡេងភាគច្រើនលើសលុបដើម្បីច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវតែប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង

47. ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ នៅក្រោយពេលដែលដំណើរការបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០៤ បានបញ្ចប់ វៀរលែងតែ អ.ប.ជ ទទួលបានសំឡេងភាគច្រើនលើសលុបចាំបាច់ដើម្បីច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ "គោលការណ៍ដែលជាមូលដ្ឋាននិងជាកត្តាកំណត់" ចំពោះគោលជំហរស្វ័យប្រវត្តិដែលថា "ការស៊ើបអង្កេតត្រូវបន្ត"[103] ដែលបានចែងក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក ក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងក្នុងវិធានផ្ទៃក្នុងនោះ តម្រូវឱ្យសំណុំរឿងនេះបន្តទៅមុខទៅ

---

នៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះត្រូវអនុវត្តចំណុចចាប់ផ្តើមអប្បបរិមានៃភ័ស្តុតាង ដែលមានចែងក្នុងមាត្រា ៦១(៧) នៃលក្ខន្តិកៈ គឺ "ភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបង្កើតមូលដ្ឋានសំខាន់ៗ ដើម្បីឱ្យជឿជាក់ថាបុគ្គលនោះពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានចោទប្រកាន់"។")។ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៦៦(៣) ("ដើម្បីផ្តន្ទាទោសជនជាប់ចោទ តុលាការត្រូវតែជឿជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យ។")។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Lubanga Dyilo*, ICC-01/04-01/06-803-tEN, អង្គបុរេជំនុំជម្រះ I សាលដីកាលើកបញ្ជាក់បទចោទ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ កថាខណ្ឌ ៣៧។ *រដ្ឋអាជ្ញា ទល់នឹង Muthaura, Kenyatta និង Ali*, ICC-01/09-02/11-382-Red, អង្គបុរេជំនុំជម្រះ II, សាលដីកាលើកបញ្ជាក់បទចោទអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៥២។

[100] ឯកសារ **D381/18** & ឯកសារ **D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ, កថាខណ្ឌ ១៦, ៣៥។

[101] ឯកសារ **D381/18** & ឯកសារ **D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ, កថាខណ្ឌ ១៦។

[102] ឯកសារ **D381/18** & ឯកសារ **D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ, កថាខណ្ឌ ១៦។

[103] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន*, កថាខណ្ឌ ១០៦-១០៧, ១១១-១១២, ១១៦-១១៧ (ជាឯកច្ឆន្ទ)។

ជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ លទ្ធផលនេះ ដូចក្នុងសំណុំរឿង ០០៤/២ ដែរ គឺជាកាតព្វកិច្ច ទោះបីជា អ.ប.ជ ខកខានមិនបានឈានដល់ការសម្រេចដែលមានសំឡេងភាគច្រើនលើសលុប ស្តីពីសុពលភាពនៃដីកាសម្រេចលើកលែងការចោទប្រកាន់ ក៏ដោយ។

48. នេះក៏ដោយសារតែគោលជំហរស្វ័យប្រវត្តិ ដែលយើងត្រូវតែគោរពនូវទូទាំងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ទាំងមូល រួមទាំងនៅក្រោយពេលបញ្ចប់ដំណើរការបណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ ផង។ ទាក់ទងនឹងចំណុចនេះ អង្គជំនុំជម្រះនេះបានសង្កត់ធ្ងន់ជាឯកច្ឆន្ទនៅក្នុងសំណុំរឿង ០០៤/២ ថា៖

> គោលការណ៍ "ដែលជាមូលដ្ឋាន និងជាកត្តាកំណត់ចំពោះគោលជំហរជាក់ស្តែង មិនអាចត្រូវបានទាត់ចោល ឬដកហូតអនុភាព និងទម្ងន់ទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយជាបណ្តាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឱ្យគោលការណ៍ស្នូលនេះក្លាយទៅជាគ្មានន័យនោះទេ។ ការសម្រេចផ្សេងពីនេះនឹងនាំទៅដល់លទ្ធផលផ្លូវច្បាប់ ដែលមិនសមហេតុសមផលជាក់ស្តែងមួយដែលរំលោភទាំងទៅលើច្បាប់អន្តរជាតិនិងច្បាប់កម្ពុជា"[104]។

49. ដូច អ.ប.ជ បានពន្យល់[105] គោលជំហរស្វ័យប្រវត្តិនេះទាញយកពីមាត្រា ៥(៤) និងមាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក[106] ដែលត្រូវបានទទួលយកដោយភាគីទាំងពីរគឺ រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក[107]។ បទប្បញ្ញត្តិទាំង

---

[104] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន,* កថាខណ្ឌ ១១២ (ជាឯកច្ឆន្ទ)។ *សូមមើលផងដែរ* កថាខណ្ឌ ១១១ ដោយបានពន្យល់អំពីគោលបំណងនៃគោលជំហរស្វ័យប្រវត្តិ គឺដើម្បី "ធានាឱ្យមានយុត្តិធម៌ដ៏ប្រសិទ្ធិភាព" និងដើម្បី "ចៀសវាងភាពទាល់ច្រកខាងកិច្ចដំណើរការនីតិវិធី ក្នុងចំណោមនោះ គឺការរារាំងដល់ប្រសិទ្ធិភាពនៃកិច្ចដំណើរការនីតិវិធី"។

[105] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន,* កថាខណ្ឌ ៩៣, ១០៧, ១១១, ១១៦-១១៧ (ជាឯកច្ឆន្ទ)។

[106] កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ៥(៤) (តម្រូវឱ្យការស៊ើបអង្កេត*ត្រូវ* បន្ត លើកលែងតែមាត្រា ៧ ត្រូវបានអនុវត្ត (សង្កត់ន័យដើម)។ មាត្រា ៧(៤) តម្រូវថា ប្រសិនបើ អ.ប.ជ មិនអាចដោះស្រាយការខ្វែងយោបល់ដោយសំឡេងភាគច្រើនលើសលុប កិច្ចស៊ើបសួរ ឬការចោទប្រកាន់នឹង*ត្រូវ* បន្តដំណើរការទៅមុខទៀត (សង្កត់ន័យដើម)។

[107] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ថ្មី ដែលតម្រូវថា ក្នុងករណីមានការខ្វែងយោបល់គ្នារវាង ស.ច.ស អវត្តមាននៃសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការនោះ ការស៊ើបអង្កេត*ត្រូវ* ធ្វើបន្ត (សង្កត់ន័យដើមត្រង់អក្សរទ្រេត)។

នេះ បង្ហាញអំពីសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយយ៉ាងច្បាស់ថា ក្នុងករណីខ្វែងយោបល់គ្នា ស.ច.ស និងសហព្រះរាជអាជ្ញា អាចបំពេញកិច្ចដោយឯករាជ្យដើម្បីធ្វើឱ្យកិច្ចដំណើរការនីតិវិធីបន្តដំណើរទៅមុខទៀត ដែលអាចបញ្ឈប់បាន*វៀរលែងតែ* មានសំឡេងភាគច្រើនលើសលុបរបស់ចៅក្រម អ.ប.ជ ប៉ុណ្ណោះ។ ការបកស្រាយនេះ គឺទទួលបានការគាំទ្រយ៉ាងពេញទំហឹងតាមរយៈភស្តុតាងបញ្ជាក់អំពីចេតនាយ៉ាងច្បាស់ក្រឡែតរបស់ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា នៅពេលដែលពួកគេបានធ្វើបញ្ចប់កិច្ចព្រមព្រៀង អ.វ.ត.ក[108]។ វាក៏ត្រូវបានអនុវត្តជាឯកច្ឆន្ទយ៉ាងស៊ីចង្វាក់

[108] ឯកសារ **D324.30** លិខិតពីលោកអគ្គលេខាធិការ អ.ស.ប ជូនចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ កំណត់សម្គាល់ជាឧបសម្ព័ន្ធពីលោក Hans Corell ជូនចំពោះលោកអគ្គលេខាធិការ កម្មវត្ថុ៖ សេចក្តីអំពាវនាវជាបន្ទាន់ពីប្រទេសកម្ពុជា - ជម្រើសដោះស្រាយការខ្វែងយបល់គ្នារវាងចៅក្រមស៊ើបអង្កេត/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ EN 01326090 (នៅថ្ងៃជាមួយគ្នាដែល អ.ស.ប បានផ្តល់ជាលើកដំបូងនូវមាត្រា៧(៤) ដែលមានពាក្យពេចន៍ទៅកាន់រាជរដ្ឋាភិបាលកម្ពុជា លោក Hans Corell ដែលជាអគ្គលេខាធិការរងទទួលបន្ទុកផ្នែកកិច្ចការច្បាប់ និងក្រុមប្រឹក្សាអ្នកច្បាប់របស់ អ.ស.ប បានកត់ត្រានូវការសន្ទនាគ្នាមួយ ជាមួយនឹងលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាប្រធានអ្នកចរចារបស់រាជរដ្ឋាភិបាលកម្ពុជា ដោយការច្រានចោលសេចក្តីអំពាវនាវរបស់គាត់ឱ្យមានលក្ខខណ្ឌតម្រូវស្តីពីមតិភាគច្រើនដាច់ខាត ដើម្បី*ធ្វើឱ្យប្រសើរឡើង* នូវការបន្តកិច្ចស៊ើបសួរ ឬការចោទប្រកាន់។ លោក Hans Corell បានពន្យល់ថា យន្តការនៃការខ្វែងយោបល់គ្នាដូចដែលបានធ្វើពង្រាងនេះ មានន័យថា "លោកត្រូវការមតិភាគច្រើនដាច់ខាតដើម្បីបញ្ឈប់កិច្ចស៊ើបសួរ ឬការចោទប្រកាន់")។ ឯកសារ **D324.36** សេចក្តីប្រកាសដោយអគ្គលេខាធិការរង លោក Hans Corell នៅពេលចាកចេញពីភ្នំពេញកាលពីថ្ងៃ១៧ ខែមីនា ឆ្នាំ២០០៣ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ EN 01326112 (លោក Hans Corell បានបញ្ជាក់នូវគោលជំហរនេះនៅខែមីនា ឆ្នាំ២០០៣ ថាក្រោយកិច្ចព្រមព្រៀង អ.វ.ត.ក មានពាក្យថា ត្រូវបានព្រមព្រៀងដោយតម្រូវឱ្យមានមតិភាគច្រើនដាច់ខាតដើម្បីបញ្ឈប់កិច្ចស៊ើបសួរ ឬការចោទប្រកាន់៖ "មានសហចៅក្រមស៊ើបអង្កេតពីររូប និងសហព្រះរាជអាជ្ញាពីររូប។ ក្នុងករណីទាំងពីរនេះ មានមន្ត្រីកម្ពុជាមួយរូប និងមន្ត្រីអន្តរជាតិមួយរូប។ ក្នុងករណីដែលពួកគាត់មានការខ្វែងយោបល់គ្នាថាតើត្រូវបន្តធ្វើកិច្ចស៊ើបសួរ ឬការចោទប្រកាន់ ការខ្វែងយោបល់គ្នានោះត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះមួយ ដែលមានចៅក្រមកម្ពុជា បី(៣)រូប និងចៅក្រមអន្តរជាតិ ពីរ(២)រូប។ នៅក្នុងអង្គជំនុំជម្រះនេះ យ៉ាងហោចណាស់ មានចៅក្រមបួន(៤)រូប ដែលត្រូវតែព្រមព្រៀងគ្នាដើម្បី*បញ្ឈប់* កិច្ចស៊ើបសួរ ឬការចោទប្រកាន់។ ប្រសិនបើមតិភាគច្រើនមិនត្រូវបានសម្រេចទេ កិច្ចស៊ើបសួរ ឬការចោទប្រកាន់នោះ *ត្រូវបន្តទៅមុខទៀត*" (សង្កត់ន័យដើម))។ *សូមមើល ផងដែរ* ឯកសារ **D381/19.1.114** លោក David Scheffer នៅក្នុងសៀវភៅរបស់ M. Cherif Bassiouni ed. "អង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា" ច្បាប់ព្រហ្មទណ្ឌអន្តជាតិ បោះពុម្ពលើកទី៣ វ៉ូលូមIII ឆ្នាំ២០០៨ ទំព័រ២៤៦ (ត្រង់កន្លែងដែល លោក David Scheffer ដែលជា ឯកអគ្គរដ្ឋទូតគោចរសហរដ្ឋអាមេរិក សម្រាប់បញ្ហាឧក្រិដ្ឋកម្មសង្គ្រាម និងបានជាប់ទាក់ទង យ៉ាងខ្លាំងនៅក្នុងការចរចានានា បានបញ្ចេញទស្សនៈដូចគ្នាថា - "មានវិធីតែមួយប៉ុណ្ណោះដែលការចោទប្រកាន់ ឬការស៊ើបអង្កេតត្រូវបាន*បញ្ឈប់* គឺថា ប្រសិនបើ [អ.ប.ជ] សម្រេចបោះឆ្នោតដោយមតិភាគច្រើនលើសលុប ឱ្យវាចប់។ សនិទានភាពនៅពីក្រោយនីតិវិធីនេះ គឺថា វារារាំងមិនឱ្យ[ស.ច.ស]មួយរូប ឬសហព្រះរាជអាជ្ញាមួយរូប ជំទាស់ទៅនឹងការស៊ើបសួរ ឬការចោទប្រកាន់

គ្នាផងដែរដោយចៅក្រម អ.ជ.ត.ក និង អ.ប.ជ[109]។ និយាយឲ្យចំ អ.ប.ជ បានបញ្ជាក់អះអាងនាពេលថ្មីៗនេះថា៖

> ក្នុងករណីដែល [អ.ប.ជ] មិនអាចស្វែងរកសំឡេងភាគច្រើនលើសលុបដើម្បីដោះស្រាយសម្រេចការខ្វែងយោបល់គ្នាទេនោះ ក្របខណ្ឌគតិយុត្តិ អ.វ.ត.ក បានចែងថា បញ្ហានេះនឹងត្រូវដោះស្រាយដោយស្ថានភាពកំណត់ (ដោយស្វ័យប្រវត្តិ) ដោយការចែងថា ការស៊ើប អង្កេតចាំបាច់ត្រូវបន្ត”[110]។

50. ដូច្នេះ ប្រសិនបើ អ.ប.ជ ខកខានមិនបានទាត់ចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើនលើសលុប នោះ អ.ជ.ស.ដ ត្រូវបានប្តឹងតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១)[111] ហើយសំណុំរឿងនេះត្រូវបញ្ជូនទៅជំនុំជម្រះ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់មិនត្រូវបានបដិសេធក៏ដោយ។ ស្របតាមគោលជំហរស្វ័យប្រវត្តិនេះ វិធាន ៧៧(១៣)(ខ) គឺជា*ច្បាប់គ្រប់គ្រងពិសេស* ទាក់ទងនឹងការចោទប្រកាន់ ដូច្នេះវាត្រូវតែមានអត្ថិភាពលុបលើពាក្យពេចន៍ទូទៅនៃវិធាន ៧៧(១៣)(ក)។ “ដីកាសម្រេចលើកលែងចោទប្រកាន់” និង “ដីកាដំណោះស្រាយ” ដូចគ្នានឹង “ដីកាបញ្ជូនរឿងទៅជំនុំជម្រះ” ដែរ គឺជាពាក្យពេចន៍ដែលត្រូវបានកំណត់និយមន័យយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង[112]។ ប្រសិនបើអ្នកតាក់តែងវិធានផ្ទៃក្នុងចង់ធ្វើការដោះស្រាយជាក់លាក់ទៅលើអនុភាពនៃការខកខានរបស់ អ.ប.ជ ដើម្បីកែប្រែដីកាសម្រេចលើកលែងចោទប្រកាន់ ម្ល៉េះពួកគេនឹងធ្វើដូច្នេះទៅហើយ។ ផ្ទុយមកវិញ វិធាន ៧៧(១៣)(ខ) ឆ្លុះបញ្ចាំងអំពីចេតនាក្នុងការអនុវត្តអាណត្តិច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក នៅពេលសហព្រះរាជ

រឿង១ខ្លួន ដោយសារការខកខានមិនបានឈានដល់ការព្រមព្រៀងគ្នាជាមួយដៃគូរបស់គាត់ ឬ ដោយគ្រាន់តែដកចេញពីការស៊ើបសួរ ឬពីការចោទប្រកាន់ បណ្តាលមកពីនយោបាយ ឬពីប្រភេទឥទ្ធិពលផ្សេងៗទៀត” (សង្កត់ន័យដើម)។

[109] សូមមើល*ខាងលើ,* កថាខណ្ឌ ២៩, ៣២-៣៣, ៣៥។

[110] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយរបស់ *អោ អាន,* កថាខណ្ឌ ១១៧ (ជាឯកច្ឆន្ទ)។

[111] វិធាន ៧៧(១៣)(ខ) ដែលកំណត់ថា គោលជំហរស្វ័យប្រវត្តិ ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានតម្កល់តាមបណ្តឹងឧទ្ធរណ៍ទេ នោះវាត្រូវតែបានប្តឹងទៅ អ.ជ.ស.ដ ដោយឈរលើមូលដ្ឋាននៃដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ វិធាន ៧៩(១) ចែងថា អ.ជ.ស.ដ ទទួលបណ្តឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះពី ស.ច.ស ឬតាមសេចក្តីសម្រេចរបស់ អ.ប.ជ ស្របជាមួយវិធាន១(២)នៃវិធានផ្ទៃក្នុង ដែលកំណត់និយមន័យអំពីពាក្យ ស.ច.ស សំដៅទៅដល់សហចៅក្រមទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ។

[112] *សូមមើល* វិធានផ្ទៃក្នុង ទំព័រ ៨៣-៨៤។

អាជ្ញា ឬ ស.ច.ស ខ្វែងយោបល់គ្នាលើដំណើរការរឿងក្តីណាមួយ៖ អវត្តមាននៃសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ក្នុងការបដិសេធការចោទប្រកាន់ ធ្វើឲ្យសំណុំរឿងរំកិលខ្លួនទៅមុខទៀតទៅកាន់ដំណាក់កាលបន្ទាប់នៃកិច្ចដំណើរការនីតិវិធី។

### *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ មិនតម្រូវឲ្យច្រានចោលសំណុំរឿង ០០៤ ទេ ក្នុងករណីដែលមិនមានដីកាដំណោះស្រាយត្រូវបានបដិសេធដោយសម្លេងភាគច្រើនលើសលុបរបស់ អ.ប.ជ*

51. អាស្រ័យហេតុនេះ បទប្បញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុង ច្បាប់ អ.វ.ត.ក កិច្ចព្រមព្រៀង អ.វ.ត.ក និងយុត្តិសាស្ត្ររបស់ អ.ជ.ត.ក និង អ.ប.ជ ដែលពាក់ព័ន្ធ *ទាំងអស់* សុទ្ធតែផ្តល់សិទ្ធិអំណាចដែលថា វា *ត្រូវតែ* បន្តទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងពេលអវត្តមានសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ដែលអាចបដិសេធដីកានេះ។ ផ្លូវឆ្ពោះទៅមុខគឺច្បាស់ក្រឡែត និងមិនត្រូវបានបដិសេធចោលដោយការស្នើឡើងរបស់ យឹម ទិត្យ ឲ្យប្រើ *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ឡើយ ដោយសារតែគ្មាន "មន្ទិលសង្ស័យ" ដែលត្រូវដោះស្រាយនោះទេ[113]។

52. ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ ដូចគ្នានឹង *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែរ ដែលមិនតម្រូវឲ្យ ស.ច.ស បដិសេធសំណុំរឿង ០០៤ ពេលដែលពួកគាត់មិនអាចឈានដល់ការព្រមព្រៀងគ្នាអំពីថាតើ យឹម ទិត្យ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬអត់នោះ វាក៏មិនអាចអនុវត្តបានផងដែរចំពោះបញ្ហានីតិវិធីនានា ដូចជាបញ្ហាមួយនេះ ដើម្បីកំណត់ថាតើ អត្ថបទពាក់ព័ន្ធគួរត្រូវបានបកស្រាយថា ត្រូវបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ដូចបានពិភាក្សារួចមកហើយ *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាផលវិបាក ឬផលដែលកើតចេញដោយផ្ទាល់ពីសច្ចធារណ៍នៃនីរទោស និងទិដ្ឋភាពមួយនៃលក្ខខណ្ឌតម្រូវថា ពិរុទ្ធភាពត្រូវតែរកឲ្យឃើញនៅពេលជំនុំជម្រះឲ្យហួសពីវិមតិសង្ស័យ[114]។ ហេតុដូច្នេះ មុខងារជាចំបងរបស់វា គឺដើម្បីដោះស្រាយបញ្ហាអង្គហេតុ និងចង្អុលប្រាប់នូវការយល់

[113] ឯកសារ **D381/18** & ឯកសារ **D382/21** បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ៤០។

[114] *សូមមើល* ផ្នែកខាងលើ កថាខណ្ឌ ៤៤។

ដឹងជាស្វ័យប្រវត្តិ ក្នុងករណីដែលពុំមានភស្តុតាងលុបបំបាត់ភាពមន្ទិលសង្ស័យផ្នែកអង្គហេតុ។[115] និយាយម្យ៉ាងទៀតថា ជាចំបង វាគឺជាវិធាននៃភស្តុតាង ហើយវាមិនមែនជាវិធានសម្រាប់ការបកស្រាយច្បាប់ទេ។

53. ស្ទម្បីតែក្នុងព្រឹត្តិការណ៍ដ៏កម្រដែលត្រូវអនុវត្តចំពោះច្បាប់ក៏ដោយ ក្នុងនាមជាគោលការណ៍ដែលជាប់ពាក់ព័ន្ធទៅនឹងសច្ចធារណ៍នៃនីរទោស *គោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ពាក់ព័ន្ធជាបឋមជាមួយនឹងការសង្ស័យទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌ*សារធាតុ*។ ត្រង់ចំណុចនេះហើយ គឺមិនមែននីតិវិធីទេ ដែលកំណត់អំពីពិរុទ្ធភាពចុងក្រោយរបស់ជនជាប់ចោទ[116]។ បញ្ហានៅត្រង់នេះ វាមិនពាក់ព័ន្ធនឹងចំណោទថាតើ យឹម ទិត្យ ជាជនគ្មាន ឬមានពិរុទ្ធចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់អ្វីទាំងអស់។ ផ្ទុយមកវិញ វាជាសំណួរថាតើ គាត់នឹងត្រូវបាននាំខ្លួនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មទាំងនោះដែរឬទេ។ ដូចបានកត់សំគាល់ពីខាងលើ[117] ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទទាំងអស់ រួមទាំង យឹម ទិត្យ ខ្លួនឯងផង ទទួលបានសច្ចធារណ៍នៃ

---

[115] *សូមមើល ឧ.* សំណុំរឿង ០០២-ឯកសារ **E50/3/1/4** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែង ខៀវ សំផន, កថាខណ្ឌ ៣១។ ឯកសារ **D378/2.1.7** [កោសលុប] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ, ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧, កថាខណ្ឌ ៦៥។ *Stakić*, IT-97-24-T, អង្គជំនុំជម្រះសាលាដំបូង II, សាលក្រម, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣, កថាខណ្ឌ៤១៦ (គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* "គឺអនុវត្តបានចំពោះការសម្រេចស្តីពីអង្គហេតុ មិនមែនអង្គច្បាប់ទេ")។

[116] *សូមមើល ឧ.* លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២២(២) ("និយមន័យនៃឧក្រិដ្ឋកម្មត្រូវតែកំណត់យ៉ាងតឹងរ៉ឹង និងមិនត្រូវពង្រីកតាមសទិសន័យឡើយ។ ក្នុងករណីមានភាពមិនច្បាស់លាស់ និយមន័យនេះត្រូវបកស្រាយក្នុងលក្ខណៈអនុគ្រោះដល់បុគ្គលដែលកំពុងស្ថិតក្រោមការស៊ើបអង្កេត ការចោទប្រកាន់ ឬការកាត់ឲ្យជាប់ទោស")។ *សូមមើលបន្ថែម រដ្ឋអាជ្ញា ទល់នឹង Laurent Gbagbo និង Charles Blé Goudé,* ICC-02/11-01/15-744, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់លោក Laurent Gbagbo និងលោក Charles Blé Goudé ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី៩ ខែមិថុនា ២០១៦ ដែលមានចំណងជើងថា "សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាដើម្បីណែនាំសក្ខីកម្មដែលបានកត់ត្រាពីមុនតាមវិធាន ៦៨(២)(ខ) និង ៦៨(៣)", ចុះថ្ងៃទី១ វិច្ឆិកា ឆ្នាំ២០១៦, កថាខណ្ឌ ៨៣ ("អង្គជំនុំជម្រះសាលាឧទ្ធរណ៍កត់សំគាល់ថា គោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវបានបង្រួមនៅក្នុងមាត្រា ២២(២) នៃលក្ខន្តិកៈនេះជាគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌដែលត្រូវយកទៅប្រើក្នុងការបកស្រាយលើនិយមន័យនៃបទឧក្រិដ្ឋ ប្រសិនបើមាននៅភាពមិនច្បាស់លាស់បានកើតឡើង")។

[117] *សូមមើល* ផ្នែកខាងលើ, កថាខណ្ឌ ៣៩។

នីរទោស លើកលែងតែ និងរហូតទាល់តែពួកគេត្រូវបានកាត់ឲ្យជាប់ទោសដោយសំឡេងភាគច្រើនលើសលុបរបស់ចៅក្រម អ.ជ.ស.ជ។

54. ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ ការអនុវត្តតាមន័យចង្អៀតរបស់វាចំពោះទ្វេគ្រោះនៃច្បាប់ គឺត្រូវបានកម្រិតត្រឹមតែមន្ទិលដែលនៅសេសសល់ក្រោយពី *ការបកស្រាយ* ដោយប្រើវិធានច្បាប់ស៊ីវិលសម្រាប់ការបកស្រាយ មានន័យថា ក្រោយពីមានការពិចារណាទៅលើពាក្យពេចន៍នៃបទប្បញ្ញត្តិនោះ ព្រមទាំងប្រព័ន្ធ (រួមទាំង ទំនាក់ទំនងរបស់វាទៅនឹងគោលការណ៍ជាមូលដ្ឋានដ៏ធំបងរបស់វា) និងគោលបំណងរបស់វា[118]។ គ្រប់អត្ថបទច្បាប់គឺសុទ្ធតែជាកម្មវត្ថុនៃការបកស្រាយ ហើយការពិតបើសិនជាមានសេណារីយ៉ូណាមួយដែលច្បាប់មិនអាចបញ្ជាក់បានច្បាស់លាស់ វាមិនមែនបង្កើតឲ្យមាន "ការសង្ស័យ" ដែលធ្វើឲ្យចុងចោទតែងតែទទួលបានផលប្រយោជន៍ពីវានោះទេ។ ដូច អ.ជ.ត.ក បានសម្រេចដែរថា *"គោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹងមិនមានភាពចាំបាច់ក្នុងការដោះស្រាយទៅលើ*ភាពខ្វះចន្លោះ* នៃច្បាប់ឡើយ[119]។

55. អ.ជ.ត.ក ក៏បានបញ្ជាក់អះអាងផងដែរថា សេចក្ដីណែនាំបែបបកស្រាយនៃវិធាន ២១ "មិនមែន [...] មានន័យថា វិធានផ្ទៃក្នុងនឹងត្រូវបានបកស្រាយដើម្បីធ្វើយ៉ាងណាឲ្យជនជាប់ចោទទទួលបានអត្ថប្រយោជន៍ណាមួយដោយស្វ័យប្រវត្តិ ក្នុងគ្រប់ស្ថានភាពជាក់ស្ដែងទាំងអស់ដែលកើតឡើងចេញពីការបកស្រាយវិធានផ្ទៃក្នុងនោះទេ" - ការពិចារណាដែលពាក់ព័ន្ធគឺថាការបកស្រាយមិនធ្វើឲ្យខូច

---

[118] សំណុំរឿង ០០២-ឯកសារ **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់, កថាខណ្ឌ ៣១ (ពន្យល់បន្ថែមថា វិធានច្បាប់ស៊ីវិលនៃការបកស្រាយច្បាប់យកចិត្តទុកដាក់ចំពោះ "ពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍របស់វា")។ សាលក្រម *Čelebići*, កថាខណ្ឌ ៤១៣ ("ប្រសិទ្ធិភាពនៃការរៀបចំពាក្យពេចន៍ដ៏តឹមរ៉ឹងនៃបទប្បញ្ញត្តិនានានៅក្នុងលក្ខន្តិកៈព្រហ្មទណ្ឌគឺថា ប្រសិនបើមានពាក្យណាមួយដែលមានន័យមន្ទិល/មានន័យពីរ ឬ ប្រយោគមិនច្បាស់លាស់ដែលនាំឲ្យមានវិមតិសង្ស័យអំពីអត្ថន័យរបស់វា *ដែលបញ្ញើនៃការរៀបចំពាក្យពេចន៍ មិនអាចដោះស្រាយបាន* នោះអត្ថប្រយោជន៍នៃមន្ទិលនេះត្រូវបានផ្ដល់ទៅឲ្យកម្មវត្ថុនោះ ហើយប្រឆាំងនឹងនីតិប្បញ្ញត្តិដែលបរាជ័យក្នុងការពន្យល់អំពីវា។ អ៊ីចឹងហើយបានជាច្បាប់លក្ខន្តិកៈព្រហ្មទណ្ឌដែលមិនច្បាស់លាស់នឹងត្រូវបានចាត់ទុកថា *ប្រឆាំងនឹងអ្នកតាក់តែង*"(សង្កត់ន័យដើម))។

[119] សំណុំរឿង ០០២-ឯកសារ **E50/3/1/4** សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំដោះលែង ខៀវ សំផន, កថាខណ្ឌ ៣១។ សំណុំរឿង០០៤/១-ឯកសារ **D308/3** ដីកាដំណោះស្រាយលើសំណុំរឿង០០៤/១, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧, កថាខណ្ឌ ២។

សិទ្ធិជាមូលដ្ឋានណាមួយរបស់ជនជាប់ចោទ[120]។ តាមពិត ការអានវិធាន២១ ទាំងមូល វាតម្រូវឱ្យច្បាប់ អ.វ.ត.ក និង វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យធ្វើយ៉ាងណាការពារដល់ផលប្រយោជន៍មិនមែនសម្រាប់តែជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទប៉ុណ្ណោះទេ គឺទាំងជនរងគ្រោះ និងដើម្បីឱ្យកិច្ចដំណើរការនីតិវិធី អ.វ.ត.ក ត្រូវតែ "ថែរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី"។ វាគឺជាគោលការណ៍ជាមូលដ្ឋាននៃច្បាប់ អ.វ.ត.ក[121] និងតុលាការអន្តរជាតិ[122] ព្រមទាំងជាដំណើរការ

---

[120] *សូមមើល ឧ.* សំណុំរឿង ០០២-ឯកសារ **E50/2/1/4** សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំដោះលែងជាបន្ទាន់, ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១, កថាខណ្ឌ ៣៩។ សំណុំរឿង ០០២-ឯកសារ **E50/3/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១, កថាខណ្ឌ ៣០ (*សូមមើលផងដែរ* កថាខណ្ឌ ៣១)។ សំណុំរឿង ០០២-ឯកសារ **E154/1/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់, ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២, កថាខណ្ឌ ១៤។

[121] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ *សូមមើលបន្ថែម* ឯកសារ **D384/5.1.1** មហាសន្និបាតអង្គការសហប្រជាជាតិ, សេចក្ដីប្រកាសស្ដីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការបំពានអំណាច, UNGA សេចក្ដីសម្រេចចិត្តលេខ 40/34 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥, គោលការណ៍ទី៤ ("ជនរងគ្រោះគួរទទួលបានការប្រព្រឹត្តចំពោះខ្លួនដោយសេចក្ដីករុណា និងការគោរពចំពោះសេចក្ដីថ្លៃថ្នូររបស់ពួកគេ។ ពួកគេមានសិទ្ធិទទួលបាននូវយន្តការនានានៃយុត្តិធម៌ និង សំណងទូទាត់ទាន់ពេលវេលាដូចមានចែងក្នុងច្បាប់ជាតិ ចំពោះការឈឺចាប់ដែលគេបានទទួលរង")។

[122] *Aleksovski*, IT-95-14/1, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកាលើបណ្ដឹងសាទុក្ខរបស់រដ្ឋអាជ្ញាស្ដីពីភាពអាចទទួលយកបាននៃភស្តុតាង ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ ២៥ ("ការអនុវត្តទស្សនៈនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ត្រឹមត្រូវក្នុងប្រយោជន៍របស់ភាគីទាំងពីរគឺអាចយល់បាន ដោយសារតែអយ្យការបំពេញកិច្ចតាងនាមឱ្យ និងក្នុងប្រយោជន៍របស់សហគមន៍ រួមបញ្ចូលទាំងផលប្រយោជន៍របស់ជនរងគ្រោះនៃអំពើល្មើសដែលបានចោទប្រកាន់នោះ (នៅក្នុងរឿងក្ដីនានានៅចំពោះមុខតុលាការអយ្យការបំពេញកិច្ចតាងនាមឱ្យសហគមន៍អន្តរជាតិ)។ គោលការណ៍នៃសមភាពនេះមិនប៉ះពាល់ដល់ការការពារជាមូលដ្ឋានដែលត្រូវបានផ្ដល់ជូនជនជាប់ចោទដោយច្បាប់ទូទៅ ឬលក្ខន្តិកៈនោះទេ និងការជំនុំជម្រះដំណើរការប្រឆាំងនឹងសវតានៃការការពារជាមូលដ្ឋានទាំងនោះឡើយ។ ការយល់តាមបែបនេះ វាពិបាកក្នុងការមើលឃើញថាតើតាមវិធីណាដែលការជំនុំជម្រះមួយអាចត្រូវបានចាត់ទុកថាយុត្តិធម៌ត្រឹមត្រូវ នៅពេលដែលជនជាប់ចោទទទួលបានផលប្រយោជន៍តាមវិធីដែលប៉ះពាល់ដល់ប្រយោជន៍របស់អយ្យការ ហួសពីការអនុវត្តតាមដ៏តឹងរឹងនូវការការពារជាមូលដ្ឋានទាំងនោះ។")។ *សូមមើលផងដែរ* *Zigiranyirazo*, ICTR-2001-73-T, អង្គជំនុំជម្រះ III សេចក្ដីសម្រេចលើញត្តិរួមរបស់អយ្យការសុំឱ្យមានការបើករឿងក្ដីរបស់ខ្លួនឡើងវិញ និងការពិចារណាឡើងវិញនូវសេចក្ដីសម្រេចចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ លើការស្ដាប់សវនាការសាក្សី Michel Bagaragaza តាមរយៈប្រព័ន្ធសោតទស្សន៍ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ១៨ ("ការការពារសេចក្ដីថ្លៃថ្នូររបស់កិច្ចដំណើរការនីតិវិធីមានន័យថា ការធានាឱ្យមានភាពយុត្តិធម៌ត្រឹមត្រូវនៅក្នុងការប្រព្រឹត្តនៃរឿងក្ដីឱ្យបានច្រើនដូចដែលភាគី*ទាំងពីរ*ពាក់ព័ន្ធ។")]។ *Karemera និងគូកន.*, ICTR-98-44-PT, អង្គជំនុំជម្រះ III, សេចក្ដី

ច្បាប់របស់ប្រទេសបារាំង និងកម្ពុជា[123] ដែលបើអនុលោមតាមគោលការណ៍នៃភាពស្មើគ្នា សិទ្ធិទទួលបានការជំនុំជម្រះក្តីមួយដែលត្រឹមត្រូវយុត្តិធម៌ មិនមែនជាកម្មសិទ្ធិរបស់ក្រុមការពារក្តីតែ

---

សម្រេចលើការបំបែកសំណុំរឿង André Rwamakuba និង Amendments របស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៧ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២៦ ("អង្គជំនុំជម្រះរំលឹកថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រឹមត្រូវអនុវត្តទៅលើទាំងភាគីការពារក្តី និងភាគីអយ្យការ។ អង្គជំនុំជម្រះត្រូវធានានូវការគោរពផលប្រយោជន៍យុត្តិធម៌។")។ *ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គូ* ICC-01/04-135-tEN, អង្គបុរេជំនុំជម្រះ I សាលដីកាលើពាក្យសុំរបស់អយ្យការសុំការអនុញ្ញាតប្តឹងសាទុក្ខសាលដីការបស់អង្គជំនុំជម្រះ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ លើពាក្យសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធី VPRS 1, VPRS 2, VPRS 3, VPRS 4, VPRS 5 និង VPRS 6, ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៣៨ ("ពាក្យ "ភាពត្រឹមត្រូវ" (*equité*) មកពីពាក្យឡាតាំង "*equus*" មានន័យថា សមតា ឬ តុល្យភាព។ ក្នុងនាមជាទស្សនៈច្បាប់ សមធម៌ ឬភាពត្រឹមត្រូវ "គឺជាលទ្ធផលផ្ទាល់នៃគីនិតយុត្តិធម៌"។ សមធម៌នៃកិច្ចដំណើរការនីតិវិធីចាំបាច់តម្រូវឲ្យមាន សមតារវាងភាគីពីរ ដែលសន្មត់យកទាំងការគោរពតាមគោលការណ៍សមធម៌ និងគោលការណ៍នៃកិច្ចដំណើរការនីតិវិធីតទល់។ តាមទស្សនៈរបស់អង្គជំនុំជម្រះ ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីរួមបញ្ចូលទាំង ការគោរពសិទ្ធិនីតិវិធីរបស់រដ្ឋអាជ្ញា មេធាវីការពារក្តី និងជនរងគ្រោះ ដូចដែលត្រូវបានធានាដោយលក្ខន្តិកៈពាក់ព័ន្ធ (នៅក្នុងប្រព័ន្ធដែលផ្តល់ឲ្យមានការចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនិតិវិធីព្រហ្មទណ្ឌ)។")។ *ស្ថានភាពក្នុងប្រទេស Uganda*, ICC-02/04-112, អង្គបុរេជំនុំ សាលដីកាលើពាក្យសុំរបស់អយ្យការសុំការអនុញ្ញាតប្តឹងសាទុក្ខដីកាសម្រេចលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ a/0010/06, a/0064/06 ដល់ a/0070/06, a/0081/06 ដល់ a/0104/06 និង a/0111/06 ដល់ a/0127/06, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ២៧ ("វាត្រូវបានគេដឹងជាទូទៅថា សិទ្ធិជំនុំជម្រះត្រឹមត្រូវនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌផ្តល់លទ្ធផលជាចំបងដើម្បីជាប្រយោជន៍របស់ចុងចោទ ឬភាគីការពារក្តី។ ប៉ុន្តែ ភាពត្រឹមត្រូវក៏លាតសន្ធឹងដល់ភាគីផ្សេងទៀតនៅក្នុងកិច្ចដំណើការនីតិវិធីផងដែរ ដូចជាភាគីអយ្យការ។")។

[123] <u>បារាំង:</u> ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ("FCCP"), Article préliminaire ("La procédure pénale doit être équitable et contradictoire et préserver l'équilibre des droits des parties. […] L'authorité judiciaire veille […] à la garantie des droits des victimes au cours de toute procédure pénale." បកប្រែក្រៅផ្លូវការ៖ កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវតែស្មើភាព និងអាចដេញដោលគ្នាបាន ហើយនឹងថែរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី។ […] អាជ្ញាធរតុលាការត្រូវធានាចំពោះសិទ្ធិរបស់ជនរងគ្រោះនូវទូទាំងកិច្ចដំណើរការនីតិវិធីទាំងមូល")។ Conseil Constitutionnel, No. 95-360, ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៩៥, កថាខណ្ឌ ៥ ("Considérant […] que le principe du respect des droits de la défense constitue un des principes fondamentaux reconnus par les lois de la République […]; qu'il implique, notamment en matière pénale, l'existence d'une procédure juste et équitable garantissant l'équilibre des droits des parties". បកប្រែក្រៅផ្លូវការ៖ "ដោយពិចារណា […] ថា គោលការណ៍គោរពសិទ្ធិរបស់មេធាវីការពារក្តី គឺជាគោលការណ៍ជាមូលដ្ឋានមួយដែលបានទទួលស្គាល់ដោយច្បាប់ [របស់ប្រទេសបារាំង]; ដែលបង្កប់ន័យ ក្នុងរឿងព្រហ្មទណ្ឌ អំពីអត្ថិភាពនៃនីតិវិធីដែលមានភាពយុត្តិធម៌ និងស្មើភាពគ្នា ដែលមានការធានាចំពោះតុល្យភាពរវាងសិទ្ធិរបស់ភាគី"]។ *សូមមើលផងដែរ* Pradel, *Manuel de Procédure Pénale* (14th edition), 1 July 2008, p. 141 ["le parquet est une partie originale à ce procès, une partie différente des autres, car il défend les intérêts de la société." បកប្រែក្រៅផ្លូវការ៖ "រដ្ឋអាជ្ញាគឺជាភាគីដើមនៃដំណើរការនេះ ជាភាគីមួយខុសពីភាគីផ្សេងទៀត ដោយសារគាត់ការពារផលប្រយោជន៍សង្គម"]។ <u>កម្ពុជា:</u> ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ៤ ("")។ បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ")។

ម្នាក់ឯងនោះទេ វាគឺជាសិទ្ធិរបស់ភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងជនរងគ្រោះផងនិង អយ្យការដែលបំពេញកិច្ចក្នុងនាម និងក្នុងផលប្រយោជន៍សង្គមកម្ពុជា និងមនុស្សជាតិទាំងអស់។ ការធ្វើតាមតែជនជាប់ចោទចំពោះបញ្ហាខាងនីតិវិធី នឹងធ្វើឱ្យមានផលប៉ះពាល់ដ៏គួរឱ្យខ្លាចទៅលើ រដ្ឋបាលរបស់អង្គជំនុំជម្រះជាមិនខាន[124]។

56. មានភាពស៊ីចង្វាក់គ្នាទាំងស្រុងជាមួយនឹងវិធាន ២ នៃវិធានផ្ទៃក្នុង៖

> នៅក្នុងអំឡុងពេលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើមានបញ្ហាណាមួយ កើតមានឡើង ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា សហចៅក្រម ស៊ើបអង្កេត ឬ អង្គជំនុំជម្រះត្រូវធ្វើការសម្រេច ដោយស្របទៅលើមាត្រា ១២(១) នៃកិច្ច ព្រមព្រៀង និង មាត្រា ២០ថ្មី ២៣ថ្មី ៣៣ថ្មី ឬ មាត្រា ៣៧ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដោយផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើ គោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ និងច្បាប់នីតិវិធី ព្រហ្មទណ្ឌជាធរមាន[125]។

និយាយឱ្យខ្លីទៅ វិធាននេះចែងថា ក្នុងករណីសេណារីយ៉ូជាក់លាក់មួយពុំលើកឡើងនៅក្នុងវិធាន ផ្ទៃក្នុងទេនោះស្ថាប័នធ្វើសេចក្តីសម្រេច*ត្រូវ*បកស្រាយបទប្បញ្ញត្តិដោយគោរពច្បាប់កម្ពុជា និង វិធាននីតិវិធីអន្តរជាតិពាក់ព័ន្ធ ហើយដោយគោរពសិទ្ធិរបស់គ្រប់ភាគី *ទាំងអស់*។ គ្មានចំណុច ត្រង់ណាមួយចែងអំពីការសម្រេចដោយស្វ័យប្រវត្តិទាំងនោះជាប្រយោជន៍ដល់ជនសង្ស័យ ជន

---

[124] *Boddaert ទល់នឹង Belgium*, លេខ 12919/87, សាលក្រម, ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩២, កថាខណ្ឌ៣៩ (“មាត្រា៦ ដាក់បញ្ហាថា កិច្ចដំណើរការនីតិវិធីរបស់តុលាការត្រូវតែឆាប់រហ័ស ប៉ុន្តែមាត្រានេះក៏បានកំណត់ផងដែរអំពីគោលការណ៍ដែលមានលក្ខណៈទូទៅច្រើនអំពីកិច្ចការរដ្ឋបាលតុលាការដ៏ត្រឹមត្រូវ។ ចំពោះកាលៈទេសៈនៃករណីនេះ ទង្វើរបស់អាជ្ញាធរ គឺមានស្របគ្នាជាមួយនឹងតុល្យភាពត្រឹមត្រូវយុត្តិធម៌ ដែលត្រូវភ្ជាប់ចំណាប់អារម្មណ៍រវាងទិដ្ឋភាពខុសៗគ្នានៃលក្ខខណ្ឌតម្រូវជាមូលដ្ឋាននេះ”)។ *Neumeister ទល់នឹងប្រទេសអូទ្រីស,* លេខ 1936/63, សាលក្រម, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៨, កថាខណ្ឌ ២១។ *សូមមើលផងដែរ* សំណុំរឿង០០២-ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣, កថាខណ្ឌ ៧៤ (“បញ្ញត្តិទាំងនេះដែលកំណត់ពីតួនាទីរបស់ចៅក្រមនៅ អ.វ.ត.ក ត្រូវបានបកស្រាយក្នុងន័យធានានូវកិច្ចការរដ្ឋបាលតុលាការដ៏ល្អប្រសើរបំផុត”)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២ (“បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់”)។

[125] សង្កត់ន័យដើម។

ត្រូវចោទ ឬជនជាប់ចោទនោះទេ។ តាមពិតនោះ វិធាន២ ចែងថា ក្នុងករណីមានចម្ងល់ កើតឡើង ដែលមិនត្រូវបានដោះស្រាយដោយវិធានផ្ទៃក្នុង វាគួរត្រូវបានដោះស្រាយ ក្នុងចំណោមបទប្បញ្ញត្តិផ្សេងទៀត ស្របតាមមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ដែលកំណត់ថា "ការស៊ើបអង្កេតត្រូវធ្វើបន្ត"។

57. បើសិនជាភាពមិនប្រាកដប្រជាខាងនីតិវិធីទាំងអស់ នឹងត្រូវបានអនុញ្ញាតជាផលប្រយោជន៍ដល់ជនត្រូវចោទដោយស្វ័យប្រវត្តិរហូតដល់ចំណុចដែលអាចរលត់កិច្ចដំណើរការនីតិវិធីបានមែន នោះវាជាការរំលោភច្បាប់នីតិវិធីកម្ពុជា (និង ច្បាប់នីតិវិធីបារាំង)។ តាមនីតិវិធីកម្ពុជា មូលហេតុនៃការរលត់បណ្តឹងអាជ្ញា គឺមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមានការកម្រិតចំពោះមរណភាពនៃជនជាប់ចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌនិង*អាជ្ញាអស់ជំនុំ*[126]។ យុត្តិសាស្ត្រនៅថ្នាក់អន្តរជាតិ[127] ក៏កំណត់ពីលក្ខខណ្ឌតម្រូវដ៏ខ្ពស់បំផុតសម្រាប់ការរំលត់ ឬផ្អាកកិច្ចដំណើរការនីតិវិធីផងដែរ[128]។ អ.ជ.ត.ក និង អ.ជ.ស.ដ ទាំងពីរសុទ្ធតែបានសម្រេចថា ខ្លួនអនុវត្តតាម អ.វ.ត.ក ថា ពួកគេគ្មានសិទ្ធិអំណាចបង្គាប់ឱ្យរលត់

---

[126] កម្ពុជា: ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៧ មានចំណងជើងថា "ការរលត់នៃបណ្តឹងអាជ្ញា"។ ("មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ៖ (១) មរណភាពនៃជនល្មើស; (២) ការផុតអាជ្ញាយុកាល; (៣) ការលើកលែងទោសជាទូទៅ; (៤)និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ឬ (៥) អាជ្ញាអស់ជំនុំ។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់")។ *សូមមើលបន្ថែម* ទាក់ទងនឹងច្បាប់នីតិវិធីបារាំង មាត្រា៦ FCCP: ("L'action publique pour l'application de la peine s'éteint par la mort du prévenu, la prescription, l'amnistie, l'abrogation de la loi pénale et la chose jugée." បកប្រែក្រៅផ្លូវការ "កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺត្រូវរលត់ដោយមរណភាពនៃចុងចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ")។

[127] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ថ្មី។

[128] ការរលត់ ឬផ្អាកកិច្ចដំណើរការនីតិវិធី ត្រូវបានអនុវត្តដោយតុលាការអន្តរជាតិដទៃទៀតម្តងម្កាលដែរ ប៉ុន្តែមានតែឧទាហរណ៍តិចតួចប៉ុណ្ណោះ និងឆ្លុះបញ្ចាំងអំពីស្ថានភាពផ្សេងៗដែលគេបានពិចារណាថា ភាពមិនអាចបន្តទៅមុខ គឺជាឧបាស្រ័យ *តែមួយគត់* ដែលអាចធានាដល់ភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬបើមិនដូច្នោះទេ គឺវាមានភាពចាំបាច់សម្រាប់ផលប្រយោជន៍យុត្តិធម៌។ *សូមមើល ឧ.* *Karadžić*, IT-95-5/18-T, អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើញត្តិស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធី, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០, កថាខណ្ឌ៤ (ទទួលស្គាល់ថា ឧបាស្រ័យហួសហេតុនៃការផ្អាកកិច្ចដំណើរការនីតិវិធីអាចនឹងធ្វើបាន បើសិនជាការរំលោភសិទ្ធិមនុស្សរបស់ជនជាប់ចោទមានលក្ខណៈធ្ងន់ធ្ងររហូតដល់ការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌មិនអាចធ្វើបាន)។ *រដ្ឋអាជ្ញា ទល់នឹង* *Lubanga Dyilo*, ICC-01/04-01/06-772, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចលើការតវ៉ារបស់មេធាវីការពារក្តីចំពោះយុត្តាធិការរបស់តុលាការ អនុលោមតាម មាត្រា ១៩(២)(ក) នៃច្បាប់លក្ខន្តិកៈ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦, កថាខណ្ឌ ៣០។

កិច្ចដំណើរការនីតិវិធីដោយសារមូលហេតុដទៃផ្សេងទៀតឡើយ[129]។ តាមពិត តាមវិធាន ៦៧(៣) គ្មានបទប្បញ្ញត្តិចែងអំពីការច្រានចោលករណីណាមួយ នៅក្នុងដំណាក់កាលនៃដីកាដំណោះស្រាយសម្រាប់ការពិចារណាផ្នែកនីតិវិធីឡើយ។

58. កិច្ចព្រមព្រៀង អ.វ.ត.ក ចែងនៅក្នុងបុព្វកថារបស់វាថា៖ "[សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥៧/២២៨] មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុង*ការស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួមជាតិ* ស្ថេរភាព សន្តិភាព និងសន្តិសុខ"[130]។ ការណ៍នេះតម្រូវឱ្យចៅក្រម និងអង្គជំនុំជម្រះ អ.វ.ត.ក ទាំងពីរ ស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា[131] និងធានាដល់ការចូលរួម

[129] សំណុំរឿង ០០២-ឯកសារ **E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២, កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-ឯកសារ **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92), ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១, កថាខណ្ឌ ១៦-១៧ (រកឃើញថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក អាចនឹងត្រូវបានរលត់តែនៅនៅក្រោមវិធាន ៨៩(១)(ខ) ដោយផ្អែកតាមមូលហេតុមួយក្នុងចំណោមមូលហេតុដែលបានកំណត់ដូចមានចែងនៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ប៉ុណ្ណោះ)។

[130] សង្កត់ន័យដើម។

[131] *សូមមើល ឧ.* វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ("ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់")"), វិធាន ៨៧(៤) ("អង្គជំនុំជម្រះ[សាលាដំបូង] អាចកោះហៅ ឬ ស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬ ទទួលយកនូវភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត")។ សំណុំរឿង ០០២-ឯកសារ **D164/3/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុករួម, ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩, កថាខណ្ឌ ៣៥ ("ជាដំបូង[ស.ច.ស] ត្រូវតែបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន ដែលមានន័យថា សហចៅក្រមស៊ើបអង្កេតបានបញ្ចប់រាល់កិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនចាត់ទុកថា ចាំបាច់ដើម្បីបង្ហាញការពិតទាក់ទងទៅនឹងអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")។ សំណុំរឿង ០០៣-ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើ [កោសលុប] បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចចេញសាឡើងវិញលើញត្តិ សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦, កថាខណ្ឌ ៣៦ (លើទំព័រ ២៥) (ចៅក្រម Beauvallet និង Baik) (បញ្ជាក់អះអាងចំពោះ "ភាពចាំបាច់ក្នុងការបញ្ជាក់នូវការពិតអំពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ")។ Cass. Crim., ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៦៦, លេខ 66-90.134 ("alors que la juridiction de renvoi est sur le point d'être saisie et que l'interêt de la manifestation de la verité continue, jusqu'au jugement à intervenir". ការបកប្រែក្រៅផ្លូវការ៖ ខណៈតុលាការជំនុំជម្រះហៀបនឹងទទួល ហើយចំណាប់អារម្មណ៍ក្នុងបង្ហាញឱ្យឃើញនូវការពិតបន្តរហូតដល់ពេលដែលសាលក្រម [សាលាដំបូង] បានចេញ")។ Cass. Crim, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧៩, លេខ 78-92.277 ("Attendu […] qu'il appartient aux juges correctionnels d'ordonner les mesures d'information qu'ils constatent avoir été omises et

ប្រកបដោយអត្ថន័យ សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងជាផ្នែកនៃការស្វែងរកការបង្រួបបង្រួមជាតិ[132]។ ពីមុន អ.ប.ជ ធ្លាប់បានកំណត់ថា "ការបញ្ចូលភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធី គឺជាការទទួលស្គាល់ការស្វែងរកការបង្រួបបង្រួមជាតិដូចបានពោលខាងលើ"[133]។ ជាថ្មីម្តងទៀត ការទាត់ចោលសំណុំរឿង ០០៤ នៅដំណាក់កាលនេះ គឺជាការរំលោភសិទ្ធិជាក់លាក់ដែលបានផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្របខណ្ឌរបស់ អ.វ.ត.ក រួមទាំងសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតុលាការ សិទ្ធិធ្វើសវនាការអំពីរឿងរ៉ាវរបស់ខ្លួន និងសិទ្ធិស្វែងរកសំណង[134]។ វាក៏នឹងបង្កើតបានជាការប្រមាថមួយចំពោះមនុស្សប្រុស ស្រីគ្រប់រូបដែលបានចូលខ្លួនមកបង្ហាញភ័ស្តុតាងដល់ ស.ច.ស ព្រមទាំងមានតម្លៃស្មើនឹងការបរាជ័យនៅក្នុងការផ្តល់នូវវិធានការយុត្តិធម៌ណាមួយដល់ជនរងគ្រោះរាប់ម៉ឺននាក់ ដែលពួកគេកំពុងតែទន្ទឹងរង់ចាំការទទួលខុសត្រូវអស់រយៈពេលជាងបួនទសវត្សរ៍មកនេះ។

## V. សេចក្តីសន្និដ្ឋាន

59. ខណៈ អ.ប.ជ បានសម្រេចនៅក្នុងសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង០០៤/២ ថា *ការចេញ*ដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា មិនត្រូវបានអនុញ្ញាតនៅក្រោមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ការណ៍នេះមិនធ្វើឱ្យមានការច្រានចោលដីកាដំណោះស្រាយទាំងពីរឡើយ។ ផ្ទុយមកវិញ ស.ព.អ សន្និដ្ឋានថាពេលនេះ អ.ប.ជ ត្រូវតែពិចារណាទៅលើឋានៈផ្លូវច្បាប់នៃដីកាដំណោះស្រាយនីមួយៗ

qu'ils déclarent utiles à la manifestation de la vérité". ការបកប្រែក្រៅផ្លូវការ៖ ដោយហេតុថា វាជារឿងចាំបាច់ដែលចៅក្រមជំនុំជម្រះបង្គាប់ឱ្យមានវិធានការស៊ើបអង្កេតដែលពួកគាត់ដឹងថា មិនបានធ្វើ ឬកំណត់ថា មានប្រយោជន៍នាំទៅដល់ការស្វែងរកការបង្ហាញការពិត")។ *សូមមើលបន្ថែម Karadžić & Mladić*, IT-95-5-R61 និង IT-95-18-R61, ការពិតិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង, ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦ កថាខណ្ឌ ៣ ("យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ [...] ត្រូវបំពេញបេសកកម្មរបស់ខ្លួនក្នុងការលាតត្រដាងការពិតអំពីអំពើដែលបានប្រព្រឹត្ត និងការឈឺចាប់ដែលបានកើតចេញអំពីវា ព្រមទាំងធ្វើការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនជាប់ចោទទាំងឡាយដែលមានការទទួលខុសត្រូវ")។

[132] សំណុំរឿង ០០២-ឯកសារ **D411/3/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១, កថាខណ្ឌ ៦៤-៦៥។

[133] សំណុំរឿង ០០២-ឯកសារ **C11/53** សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨, កថាខណ្ឌ ៣៧។

[134] វិធាន ២៣(១), វិធាន ៨០(២) នៃវិធានផ្ទៃក្នុង។

ដូចដែលខ្លួនបានអនុវត្តចំពោះសំណុំរឿង ០០៤/២ ដើម្បីកំណត់ថាតើ ដីកាដំណោះស្រាយណាមួយ (ឬទាំងពីរ) មានកំហុសខាងនីតិវិធី ឬសារធាតុដែលតម្រូវឱ្យបដិសេធ។

60. ស.ព.អ សន្និដ្ឋានថា អាស្រ័យដូចមូលហេតុដែលបានកំណត់ខាងលើ[135] និងមូលហេតុក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[136] ដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរតែត្រូវបានតម្កល់។ ផ្ទុយទៅវិញ ការបំភ្លឺរបស់ អបជ នាពេលថ្មីៗនេះអំពីច្បាប់ជាធរមាននៅក្នុងសំណុំរឿង ០០៤/២ បង្ហាញឱ្យឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានទុកជាមោឃៈ និងគ្មានសុពលភាពផ្លូវច្បាប់[137]។ ចំពោះអង្គសេចក្តីសំខាន់ៗនៃដីកាសម្រេចនេះវិញ ដូចបានកំណត់យ៉ាងពិស្តារនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ[138] គឺថាដីកាសម្រេចលើកលែងចោទប្រកាន់ក៏មានកំហុសខាងអង្គហេតុ និងអង្គច្បាប់ជាច្រើនដែលធ្វើឱ្យខូចដល់ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ ដែលបានកំណត់ថា យឹម ទិត្យ មិនមែនជាជនម្នាក់នៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

61. ទោះនៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ បើសិនជា អ.ប.ជ ខកខានមិនអាចឈានដល់សេចក្តីសម្រេចមួយដែលមានសំឡេងលើសលុបក្នុងការបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ នោះដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ស្របតាមពាក្យពេចន៍ច្បាស់លាស់នៃវិធាន ៧៧(១៣)(ខ) និង វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។

## VI. ឧបាស្រ័យដែលស្នើឡើង

62. អាស្រ័យដោយមូលហេតុដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើដល់អង្គបុរេជំនុំជម្រះ ៖

---

[135] *សូមមើល យោងខាងលើ* កថាខណ្ឌ ២៨-៣៦, ៣៨-៤៦។

[136] ឯកសារ **D382/27** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០៤, ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

[137] *សូមមើល យោងខាងលើ* កថាខណ្ឌ ២៨-៣៨។

[138] ឯកសារ **D381/19** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់។

i. ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរនៅក្នុងសំណុំរឿង ០០៤;

ii. បដិសេធដីកាសម្រេចលើកលែងចោទប្រកាន់;

iii. តម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ; និង

iv. បញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដោយឈរលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ | លោកស្រី **Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature and stamp: CO-PROSECUTORS CO-PROCUREURS E.C.C.C. C.E.T.C.] |